ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

១២-១០-២០០៧ -ព្រះរាជក្រម នស/រកម/១០០៧/០២៦ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋ អ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញ និងការការពារវិនិយោគ ៨៥០០

២-ព្រះរាជក្រឹត្យ

០៦-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៤៩៨ ស្តីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ គិតចាប់ពីថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៧ ជូនមន្ត្រីរាជការចំនួន ១៤ រូប ៨៥២៦

០៦-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៤៩៩ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សាឯកឧត្តម **ម៉ឹន ឈឿន** ឧបនាយករដ្ឋមន្ត្រី ៨៥២៨

០៦-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០០ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **ទីអ គ្រឿនមុន្នី** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា ៨៥២៩

០៦-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០១ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការ ស៊ីវិលរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ៨៥៣០

០៦-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០២ ស្តីពីការតែងតាំងលោក **ស្រ៊ុន សំណាង** ជា ឧកញ៉ា ៨៥៤៨

០៦-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៣ ស្តីពីការដាក់ ឯកឧត្តមចំនួន ០២ រូប នៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ៨៥៤៩

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៤ ស្តីពីការប្រោសព្រះរាជទានគោរមងារ សម្តេច **ហេង សំរិន** ជា **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ៨៥៥០

១២-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៥ ស្តីពីការប្រោសព្រះរាជទានគោរមងារ សម្តេច **ជា ស៊ីម** ជា **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ៨៥៥១

-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥០៦ ស្តីពីការប្រោសព្រះរាជទានគោរមងារ សម្តេច **ហ៊ុន សែន** ជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ៨៥៥២

II~ក្រុមប្រឹក្សាធម្មនុញ្ញ

សេចក្តីសំរេច

១០-២០០៧ -សេចក្តីសំរេចលេខ ៤០/២០០៧ កបធ.សសរ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ ៨៥៥៣

III~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

-១០-២០០៧ -អនុក្រឹត្យលេខ ១៤៩ អនក្រ.បក ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបំរុងសត្វគ្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបុរីជលសា និង ស្រុកកោះអណ្តែត ខេត្តតាកែវ ៨៥៦២

-១០-២០០៧ -អនុក្រឹត្យលេខ ១៥០ អនក្រ.បក ស្តីពីការទទួលស្គាល់ **វិទ្យាស្ថានប្រាយហ្សប** ៨៥៦៨

១០-២០០៧ -អនុក្រឹត្យលេខ ១៥១ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមជូនក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ៨៥៧១

-១០-២០០៧ -អនុក្រឹត្យលេខ ១៥២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨៥៧៣

-១០-២០០៧ -អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨៥៧៥

១០-២០០៧ -អនុក្រឹត្យលេខ ៨១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៥៧៧

១០-២០០៧ -អនុក្រឹត្យលេខ ៨២០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៥៧៩

-១០-២០០៧ -អនុក្រឹត្យលេខ ៨២១ អនក្រ.តត ស្តីពីការកែសំរួលថ្នាក់ និងតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ៨៥៨០

០៥-១០-២០០៧ -អនុក្រឹត្យលេខ ៨២២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៥៨២

០៩-១០-២០០៧ -អនុក្រឹត្យលេខ ៨២៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៥៨៣

០៩-១០-២០០៧ -អនុក្រឹត្យលេខ ៨២៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨៥៨៤

០៥-១០-២០០៧ -អនុក្រឹត្យលេខ ៨២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៨៦

-១០-២០០៧ -អនុក្រឹត្យលេខ ៨២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៨៨

១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨២៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៥៥០
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥១
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥២
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៣០ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៨៥៥៣
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥៤
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥៥
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥៦
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥៧
១៥-១០-២០០៧ -អនុក្រឹត្យលេខ ៨៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៥៨

២_សេចក្តីសំរេច

១៦-១០-២០០៧ -សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការចាត់តាំងមន្ត្រីរាជការ ៨៥៥៩
១៧-១០-២០០៧ -សេចក្តីសំរេចលេខ ៥៣ សសរ ស្តីពីការកែសំរួលសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌ នៅកម្ពុជា ៨៦០០

IV_ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីសំរេច

០៨-១០-២០០៧ -សេចក្តីសំរេចលេខ ៥០ សសរ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិវិភាគទានស្រាវជ្រាវ នៅរាជបណ្ឌិតសភាកម្ពុជា ៨៦០២

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៥-១០-២០០៧ -ប្រកាសលេខ ១០១៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេឃ្វើ យីង អ៊ិនវេសមេន ខនស្ត្រាក់សិន អ៊ីមផត អិចផត បង្កើតរោងចក្រ " ផលិតទឹកបរិសុទ្ធ " ដែលមានឈ្មោះថា " អេឃ្វើ យីង អ៊ិនវេសមេន ខនស្ត្រាក់សិន អ៊ីមផត អិចផត " ៨៦០៨
០៥-១០-២០០៧ -ប្រកាសលេខ ១០១៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេស្សា ហ្វារអ៊ើម៉ាយល៍ ឧបករហ្សិន បង្កើតរោងចក្រ " ផលិតម្សៅមី " ដែលមានឈ្មោះថា " អេស្សា ហ្វារអ៊ើម៉ាយល៍ ឧបករហ្សិន " ៨៦១១

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

១៨-១០-២០០៧ -ប្រកាសលេខ ៤៥០ ប្រក.កសក ស្តីពីការបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើ តាបែន ៨៦១៣

១៨-១០-២០០៧ -ប្រកាសលេខ ៤៥១ ប្រក.កសក ស្តីពីការបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើ ស្នួលទ្រេត ៨៦១៧

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

០៥-១០-២០០៧ -ប្រកាសលេខ ៤២៧ ប្រក.សក.បធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំៗ ៨៦២០

ព្រះរាជក្រម

នស/រកម/១០០៧/០២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញនិងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • MINISTERE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋ អ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញនិងការការពារវិនិយោគ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.១០០៧/០២៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

លេខ: ៤៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជីនកេន

កិច្ចព្រមព្រៀង

រវាង

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

និង

រដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

ស្តីពី

ការជំរុញ និងការការពារវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានចាប់ពីពេលនេះតទៅហៅថា " ភាគីនៃកិច្ចសន្យា "

ក្នុងគោលបំណងបង្កើតនូវលក្ខខ័ណ្ឌសមស្របសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដ៏ធំធេងរវាងភាគីទាំងពីរ និង ជាពិសេស សំរាប់ការវិនិយោគនៃវិនិយោគិន នៃរដ្ឋមួយនៅលើទឹកដី នៃរដ្ឋមួយទៀត ដោយផ្អែកលើ គោលការណ៍ ស្មើភាព និងមានផលប្រយោជន៍ទៅវិញទៅមក ។

ដោយទទួលស្គាល់ថា ការលើកទឹកចិត្ត និងការការពារទៅវិញទៅមកនៃការធ្វើវិនិយោគមានប្រយោជន៍ក្នុង ការជំរុញការផ្តួចផ្តើមអាជីវកម្ម និងលើកស្ទួយភាពរុងរឿងនៃប្រទេសទាំងពីរ ។

ដោយព្រមព្រៀងថា រចនាសម្ព័ន្ធដែលមានស្ថេរភាពសំរាប់វិនិយោគ នឹងបង្កើនការប្រើប្រាស់ធនធានសេដ្ឋកិច្ច អោយមានប្រសិទ្ធិភាព និងលើកស្ទួយភាពរុងរឿង ។

ដោយមានបំណងចុះនូវកិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ បានព្រមព្រៀងគ្នាដូចតទៅ :

មាត្រាទី ១

និយមន័យ

គោលបំណងនៃកិច្ចព្រមព្រៀង :

១- ពាក្យ "**វិនិយោគទុន**" មានន័យថា

(ក) ទ្រព្យ ឬវត្ថុ ដែលវិនិយោគទាក់ទងជាមួយសកម្មភាពសេដ្ឋកិច្ចពាក់ព័ន្ធនឹងការធ្វើអាជីវកម្មរបស់អ្នកវិនិយោគនៃភាគីមួយ ធ្វើនៅលើទឹកដីនៃភាគីខាងទៀតក្នុងការធ្វើការបង្កើត ការរៀបចំ ឬការគ្រប់គ្រងឧស្សាហកម្មពាក់ព័ន្ធនឹងការរៀបចំដំណើរការនៅក្នុងផលិតកម្ម ការចែកចាយ ឬការកែច្នៃទូរវាល់ទំនិញ ឬការបំលែង និងការទាញយកផលធនធានរ៉ែ និងផលិតផលផ្សេងទៀតដូចមានបញ្ជាក់ថាមានប្រយោជន៍ដល់ភាគីជាប់កិច្ចសន្យា។

(ខ) "ពាក្យវិនិយោគ មិនរាប់បញ្ចូលផងទេនូវកិច្ចសន្យាក្នុងការផ្តល់សេវាកម្ម និងកិច្ចសន្យាសាងសង់។"

(គ) "សំរាប់ករណីកិច្ចសន្យារវាងនិវាសនជននៃភាគីជាប់កិច្ចសន្យាខាង ជាមួយនិវាសនជននៃភាគីជាប់កិច្ចសន្យាខាងទៀត ខ្លឹមសារនិងលក្ខខ័ណ្ឌនៃកិច្ចសន្យាដែលចុះហត្ថលេខារវាងភាគីនោះនឹងមិនមានពាក់ព័ន្ធជាមួយបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះទេ ហើយនឹងគ្រប់គ្រងដោយខ្លឹមសារ និងលក្ខខ័ណ្ឌនៃកិច្ចសន្យានោះ ។"

(ឃ) កិច្ចសន្យាស្តីពីការកំណត់កាលបរិច្ឆេទ នឹងមិនអាចចាត់ដូចជាការវិនិយោគទេ។

២- ពាក្យ "**ផលចំណូល**" មានន័យថា រូបិយវត្ថុបានមកពីការវិនិយោគ រួមមានប្រាក់ចំណេញ ណាមួយ ការប្រាក់ ផលកំរៃ ប្រាក់ចំណេញនៃភាគហ៊ុន កំរៃឈ្នួល ឬកំរៃ ។

៣- ពាក្យ "**វិនិយោគិន**" មានន័យចំពោះភាគីជាប់កិច្ចសន្យានិមួយៗ :

(ក) រូបវ័ន្តបុគ្គលជាជនជាតិនៃភាគីជាប់កិច្ចសន្យាដែលធ្វើការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាខាងទៀត ។

(ខ) នីតិបុគ្គលដែលបង្កើតឡើង ឬរៀបចំតាមរបៀបផ្សេងទៀតស្របតាមច្បាប់ និងបទបញ្ញត្តិ

នៃភាគីជាប់កិច្ចសន្យាម្ខាងមានទីស្នាក់ការ និងធ្វើសកម្មភាពជំនួញពិតប្រាកដនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ហើយបានធ្វើវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៤- ពាក្យ "រូបិយប័ណ្ណធ្វើផ្លាស់ដោយសេរី" មានន័យថា រាល់រូបិយបណ្ណ ដែលអាចប្រើប្រាស់បានជាទូទៅសំរាប់ការទូទាត់ក្នុងអាជីវកម្មអន្តរជាតិ និងធ្វើពាណិជ្ជកម្មយ៉ាងទូលាយនៅក្នុងទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ ។

៥- ពាក្យ "ទឹកដី" មានន័យថា

- ចំពោះព្រះរាជាណាចក្រកម្ពុជា គឺទឹកដីដែលព្រះរាជាណាចក្រកម្ពុជា មានអធិបតេយ្យភាព ឬយុត្តាធិការ ។
- ចំពោះសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន គឺទឹកដីដូចដែលបានផ្តល់និយមន័យនៅក្នុងមាត្រា(១) និង (២) នៃរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ។

មាត្រាទី ២
ការជំរុញ និងការគាំពារវិនិយោគ

១- ភាគីនីមួយៗ ត្រូវលើកទឹកចិត្ត និងបង្កើតលក្ខខ័ណ្ឌសមស្របដល់វិនិយោគិននៃភាគីម្ខាងទៀតក្នុងការធ្វើវិនិយោគក្នុងទឹកដីរបស់ខ្លួន ហើយទទួលស្គាល់ការវិនិយោគនោះ ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិរបស់ខ្លួន ។

២- ដើម្បីលើកទឹកចិត្តនូវលំហូរវិនិយោគទៅវិញទៅមក ភាគីនីមួយៗត្រូវខិតខំជូនដំណឹងទៅភាគីម្ខាងទៀត តាមសំណើនៃភាគីនោះនូវឱកាសវិនិយោគក្នុងទឹកដីរបស់ខ្លួន ។

៣- ភាគីនីមួយៗ ត្រូវធ្វើការពិចារណាជាបន្ទាន់ និងក្នុងគោលបំណងល្អ ក្នុងករណីចាំបាច់ស្របទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ខ្លួននូវសំណើសុំការអនុញ្ញាតទាំងឡាយទាក់ទងទៅនឹងសកម្មភាពនៃទីប្រឹក្សា ឬអ្នកជំនាញការដែលតំរូវដោយវិនិយោគិននៃភាគីម្ខាងទៀត ។

៤- ភាគីនីមួយៗត្រូវអនុវត្តច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់ខ្លួនទាក់ទងនឹងការចូល ការស្នាក់នៅ និងការបំរើការងារនៃរូបវន្តបុគ្គលដោយពិនិត្យឱ្យបានល្អ និងផ្តល់ការយកចិត្តទុកដាក់ចំពោះសំណើនៃ

បុគ្គលិកសំខាន់ៗ (ពលរដ្ឋនៃភាគី) រួមមានអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ និងបុគ្គលិកបច្ចេកទេសដែលបំរើការអោយគោលបំណងនៃការវិនិយោគ ដើម្បីចូលមកស្នាក់នៅមួយរយៈ និងធ្វើការនៅក្នុងទឹកដីរបស់ខ្លួន។ សមាជិកគ្រួសារដែលជិតបំផុត (សហព័ទ្ធនិងកូនក្នុងបន្ទុក) នៃបុគ្គលិកសំខាន់ៗនោះត្រូវបានផ្តល់អោយដូចគ្នាចំពោះការចូល និងការស្នាក់នៅមួយរយៈក្នុងប្រទេសនៃភាគីម្ចាស់ផ្ទះ ។

មាត្រានី ៣
ការការពារវិនិយោគ

១- ភាគីនិមួយៗ ត្រូវបង្កើនក្នុងទឹកដីរបស់ខ្លួននូវកិច្ចការពារយ៉ាងពេញលេញ និងមានសុវត្ថិភាពចំពោះការវិនិយោគ និងផលចំណូលនៃវិនិយោគិនរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត ។ គ្មានភាគីណាមួយត្រូវប្រឈមដោយវិធានការមិនសមហេតុផល ឬរើសអើងក្នុងការអភិវឌ្ឍន៍ ការគ្រប់គ្រង ការប្រើប្រាស់ ការអាស្រ័យផល ការពង្រីកការលក់ និងប្រសិនបើមាន សំរាប់ការជំរះបញ្ជីវិនិយោគឡើយ ។ ភាគីជាប់កិច្ចសន្យានិមួយៗ ត្រូវពិនិត្យនូវបណ្តាកាតព្វកិច្ចផ្សេងៗដែលអាចមានទំនាក់ទំនងចំពោះការវិនិយោគរបស់វិនិយោគិន នៃភាគីម្ខាងទៀត ។

២- ការវិនិយោគ ឬផលចំណូលនៃប្រាក់ចំណេញរបស់វិនិយោគិននៃភាគីម្ខាងនៅលើទឹកដីនៃភាគីម្ខាងទៀត ត្រូវទទួលបាននូវសមភាព និងភាពស្របតាមច្បាប់ តាមបទបញ្ញត្តិនៃភាគីជាម្ចាស់ទឹកដីនោះ និងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។

មាត្រានី ៤
ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិដែលទទួលនូវការអនុគ្រោះបំផុត

១- ភាគីនិមួយៗ ត្រូវផ្តល់នូវការយល់ព្រមក្នុងទឹកដីរបស់ខ្លួនលើការធ្វើវិនិយោគ និងផលចំណូលរបស់វិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវប្រព្រឹត្តិកម្មមិនតិចជាងអ្វីដែលខ្លួនបានផ្តល់អោយទៅវិនិយោគិន និងទិន្នផលរបស់វិនិយោគិនខ្លួនឯងនោះឡើយ ឬការវិនិយោគ និងទិន្នផល

របស់វិនិយោគិននៃរដ្ឋទីបីណាមួយក៏ដោយឱ្យតែប្រព្រឹត្តិកិច្ចនោះមានលក្ខណៈអនុគ្រោះច្រើនចំពោះវិនិយោគិនដែលពាក់ពន្ធ័ ។

២- ភាគីជាប់កិច្ចសន្យា ត្រូវផ្តល់ការយល់ព្រមក្នុងទឹកដីរបស់ខ្លួនទៅអោយវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀតទាក់ទងនឹងការគ្រប់គ្រង ការថែរក្សា ការផ្តល់ ឬការទទួលការងារ ការប្រើប្រាស់ ឬការចាត់ចែងនៃការវិនិយោគនូវប្រព្រឹត្តិកិច្ច មិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមផ្តល់ជូនវិនិយោគិននៃរដ្ឋទីបីណាមួយ ។

៣- បណ្តាបញ្ញត្តិនៃវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះមិនត្រូវបានបកស្រាយដើម្បីតំរូវឱ្យភាគីជាប់កិច្ចសន្យាម្ខាងផ្តល់ឱ្យវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវផលប្រយោជន៍នៃប្រព្រឹត្តិកម្ម ភាពអនុគ្រោះ ឬបុព្វសិទ្ធិណាមួយដែលភាគីជាប់កិច្ចសន្យាពីមុនធ្លាប់បានផ្តល់ឱ្យដោយផ្អែកលើ :

ក- កិច្ចព្រមព្រៀងណាមួយដែលមានស្រាប់ ឬពេលអនាគត ស្តីពីសហពន្ធ័គយ ឬសហពន្ធ័សេដ្ឋកិច្ចតំបន់ពាណិជ្ជកម្មសេរី ឬកិច្ចព្រមព្រៀងអន្តរជាតិប្រហាក់ប្រហែលដែលភាគីជាប់កិច្ចសន្យាណាមួយស្ថិតនៅជាសមាជិក ឬអាចក្លាយជាសមាជិកនៅពេលខាងមុខ ។

ខ- កិច្ចព្រមព្រៀងអន្តរជាតិ ឬការរៀបចំរួលណាមួយដែលមានការពាក់ព័ន្ធទាំងស្រុង ឬមួយផ្អែកទៅនឹងបញ្ហាពន្ធដារ ។

មាត្រាទី ៥

ការដកហូត

១- ភាគីជាប់កិច្ចសន្យាមិនត្រូវដកហូត ឬធ្វើជាតូបនីយកម្មដោយផ្ទាល់ ឬដោយប្រយោលលើការវិនិយោគរបស់វិនិយោគិននៃភាគីជាប់កិច្ចសន្យាផ្សេងទៀតនៅលើទឹកដីរបស់ខ្លួនឡើយ ឬប្រកាន់យកនូវវិធានការណាមួយ ឬគ្រប់វិធានការដែលមានសមមូល (ដែលចាប់ពីនេះតទៅហៅថាការដកហូត) លើកលែង :

ក- សំរាប់គោលបំណងជាផលប្រយោជន៍សាធារណៈ

ខ- លើមូលដ្ឋានគ្មានការរើសអើង

គ- ស្របទៅតាមនីតិវិធីនៃច្បាប់ និង

ឃ- ភ្ជាប់ជាមួយការទូទាត់សំណង យ៉ាងឆាប់រហ័ស គ្រប់ចំនួន និងជំងឺចិត្តដែលមាន ប្រសិទ្ធិភាព ។

២- សំណងបែបនេះត្រូវធ្វើការទូទាត់ដោយគ្មានការពន្យារពេល ។

៣- សំណងបែបនេះត្រូវមានទឹកប្រាក់ស្មើនឹងតំលៃទីផ្សារដ៏ត្រឹមត្រូវនៃតំលៃវិនិយោគដែលបានដកហូតមុនពេលដែលការដកហូតត្រូវបានកើតមានឡើង ។ តំលៃទីផ្សារដ៏ត្រឹមត្រូវនឹងមិនបង្ហាញពីការប្រែប្រួលតំលៃណាមួយឡើយ ព្រោះថាការដកហូតត្រូវដឹងជាសាធារណៈពីមុនរួចហើយ ។

៤- សំណងបែបនេះត្រូវបានអនុវត្តបានដោយពេញលេញ និងអាចផ្ទេរបានដោយសេរី ។

៥- វិនិយោគិននៃភាគីជាប់កិច្ចសន្យាដែលរងនូវការដកហូតដោយភាគីជាប់កិច្ចសន្យាម្ខាងទៀត មានសិទ្ធិដើម្បីពិនិត្យមើលភ្លាមៗនូវករណីរបស់ខ្លួន រួមមានការវាយតំលៃលើការវិនិយោគរបស់ខ្លួន និងការទូទាត់សំណងស្របទៅតាមបទបញ្ញត្តិនៃមាត្រានេះ ដោយអាជ្ញាធរ តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច និងឯករាជ្យផ្សេងទៀតនៃភាគីជាប់កិច្ចសន្យាដែលជាអ្នកដកហូត ។

មាត្រាទី ៦

សំណងសំរាប់ការខូចខាត ឬការបាត់បង់

១- នៅពេលដែលការវិនិយោគធ្វើឡើងដោយវិនិយោគិននៃភាគីណាមួយទទួលរងនូវការខាតបង់ ឬខូចខាតដែលបណ្តាលមកពីសង្គ្រាម ឬជំលោះអាវុធផ្សេងៗទៀត ភាពចលាចលស៊ីវិល បដិវត្ត កុប្បកម្ម ឬហេតុការណ៍ប្រហាក់ប្រហែលនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ការវិនិយោគនោះត្រូវតែបានយល់ព្រមដោយភាគីជាប់កិច្ចសន្យា ដែលជាម្ចាស់ទឹកដីនោះនូវប្រព្រឹត្តិកិច្ចដូចជាការធ្វើអោយដូចដើមវិញ ការប៉ះប៉ូវសំណង ឬដំណោះស្រាយណាមួយផ្សេងទៀតដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលបានផ្តល់ឱ្យវិនិយោគិនរបស់ខ្លួន ឬវិនិយោគិននៃរដ្ឋទីបីណាមួយឱ្យតែប្រព្រឹត្តកិច្ចនោះមានភាពអនុគ្រោះច្រើនសំរាប់វិនិយោគិនពាក់ព័ន្ធ ។ ទោះជាយ៉ាងនេះក៏ដោយការខាតបង់ដែលកើតចេញពីហានិភ័យធម្មតានៃអាជីវកម្ម នឹងមិនចាត់ទុកជាករណីត្រូវបានទទួលការទូទាត់សំណងទេ ។

២- ដោយមិនប៉ះពាល់ដល់វាក្យខណ្ឌទី ១ នៃមាត្រានេះ វិនិយោគិននៃភាគីជាប់កិច្ចសន្យាដែលស្ថិតនៅក្នុងហេតុការណ៍ណាមួយផ្អែកលើវាក្យខ័ណ្ឌនេះ បានរងការខូចខាត ឬការខាតបង់នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលបណ្តាលមកពី :

ក- ការរឹបអូសទ្រព្យសម្បត្តិ ឬផ្នែកខ្លះនៃទ្រព្យសម្បត្តិរបស់ខ្លួន ឬជាចំណែកនៃទ្រព្យសម្បត្តិដោយកំលាំងទ័ព ឬអាជ្ញាធរ ។

ខ- ការបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួនដោយកងកំលាំង ឬអាជ្ញាធរដែលមិនមែនជាមូលហេតុនៃការប្រយុទ្ធគ្នាឬដែលមិនស្ថិតក្នុងស្ថានភាពចាំបាច់ទេនោះ នឹងត្រូវទទួលបាននូវការធ្វើអោយដូចដើមវិញភ្លាមៗ ហើយការទូទាត់សំណងសំរាប់ការខូចខាត ឬការខាតបង់ត្រូវឆាប់រហ័សគ្រប់ចំនួន និងជាក់ស្តែងនៅទីកន្លែងដែលមានការរឹបអូស ឬការបំផ្លាញនោះ ។ ការទូទាត់ត្រូវធ្វើដោយរូបិយបណ្ណ័ដែលអាចប្តូរបានដោយសេរី និងពុំមានការពន្យាពេលឡើយ ។

មាត្រាទី ៧
ការផ្ទេរ

១- ភាគីនិមួយៗត្រូវអនុញ្ញាតថា រាល់ការទូទាត់ទាក់ទងទៅនឹងការវិនិយោគក្នុងទឹកដីរបស់ខ្លួននៃវិនិយោគិនរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត អាចផ្ទេរដោយសេរីនៅក្នុង ឬទៅខាងក្រៅទឹកដីរបស់ខ្លួនដោយគ្មានការពន្យារពេល ។ ទោះបីជាមិនដាច់ខាតក្តី ការផ្ទេរនេះរាប់បញ្ចូលជាពិសេសនូវ :

ក- ដើមទុនដំបូង និងទឹកប្រាក់បន្ថែមដើម្បីទ្រទ្រង់ ឬចម្កើនវិនិយោគ

ខ- ផលចំណូលដូចបានផ្តល់និយមន័យក្នុងវាក្យខ័ណ្ឌ ២ នៃមាត្រា (១) នៃកិច្ចព្រមព្រៀងនេះ

គ- ការទូទាត់សងដែលចែងក្នុងកិច្ចសន្យា រួមមានកិច្ចព្រមព្រៀងខ្ចីប្រាក់ទាក់ទងនឹងការវិនិយោគ

ឃ- ប្រាក់ដែលបានមកពីការលក់ ឬការជំរះបញ្ជីនៃការវិនិយោគទាំងអស់ ឬមួយផ្នែក

ង- ការទូទាត់ដែលបានមកពីការទូទាត់សំណងដូចមានចែងក្នុងមាត្រា (៥) (៦) និង (៨) នៃកិច្ចព្រមព្រៀងនេះ

ច- ការទូទាត់ដែលបានមកពីការដោះស្រាយលើករណីជំលោះវិនិយោគ

ឆ- ចំណូលឬប្រាក់បំណាច់នៃបុគ្គលិកមកពីបរទេសដែលបំរើការងារទាក់ទងនឹងការវិនិយោគ ស្របតាមមាត្រា (២) នៃកិច្ចព្រមព្រៀងនេះ ។

២- ភាគីនីមួយៗត្រូវធានាថា ការផ្ទេរដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះត្រូវធ្វើដោយរូបិយវត្ថុដែលអាចប្តូរបានដោយសេរីទៅតាមអត្រាជាទូទៅ នៃការប្តូរប្រាក់ដែលកំណត់ដោយអ្នកធ្វើអាជីវកម្មមានច្បាប់ ហើយដែលមានសុពលភាពក្នុងថ្ងៃផ្ទេរនៅក្នុងទឹកដីនៃភាគីដែលមានការវិនិយោគ ។

៣- ភាគីនីមួយៗត្រូវធានាថា ការប្រាក់ "ប្រសិនជាមាន" នៅក្នុងការទូទាត់ ការប៉ះប៉ូវសំណងដែលបានអូសបន្លាយពេលឬមិនបានអនុវត្តក្រោយថ្ងៃកំណត់សំរាប់ការទូទាត់ ត្រូវធ្វើការគណនាជាមួយគ្នានឹងការប៉ះប៉ូវសំណង សំរាប់រយៈពេលដែលគិតចាប់ផ្តើមពីការកើតមាននៃបញ្ហា ដូចមានចែងក្នុងមាត្រា (៥) (៦) និង(៨) រហូតដល់ថ្ងៃដែលការផ្ទេរសំណង ហើយការទូទាត់នេះ និងមានប្រសិទ្ធិភាពអនុវត្តស្របតាមបទបញ្ញត្តិនៃវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះ ។

មាត្រាទី ៨
ឧបត្ថម្ភ

ក្នុងករណីដែលភាគីជាប់កិច្ចសន្យាមួយ ឬភ្នាក់ងារដែលបានតែងតាំងបានផ្តល់នូវការទូទាត់ក្រោមរូបភាពជាសំណងការធានាឬកិច្ចសន្យាធានារ៉ាប់រង ដើម្បីទប់ទល់ជាមួយហានិភ័យមិនមែនពាណិជ្ជកម្មទាក់ទងនឹងការវិនិយោគរបស់វិនិយោគិនរបស់ខ្លួននៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាខាងទៀតភាគីជាប់កិច្ចសន្យានោះ ត្រូវទទួលស្គាល់ការផ្ទេរសិទ្ធិ ឬការទាមទារនៃវិនិយោគិននៃភាគីជាប់កិច្ចសន្យាមុន ឬភ្នាក់ងារដែលបានតែងតាំង និងសិទ្ធិនៃភាគីជាប់កិច្ចសន្យាមុននោះឬភ្នាក់ងារដែលបានតែងតាំង ដើម្បីប្រតិបត្តិកិច្ចការដោយយោងទៅលើឧបទេសកម្មនៃសិទ្ធិនោះ និងការទាមទារដែលមានវិសាលភាពដូចគ្នានឹងអ្នកផ្តល់សិទ្ធិអនុវត្តផ្ទាល់ដែរ ។

មាត្រាទី ៩
ការអនុវត្តន៍បណ្តាបទបញ្ញត្តិនានា

ប្រសិនបើបណ្តាបទបញ្ញត្តិនៃច្បាប់របស់ភាគីជាប់កិច្ចសន្យាណាមួយ ឬកាតព្វកិច្ចនៃច្បាប់អន្តរជាតិ ដែលមាននាពេលបច្ចុប្បន្នឬបានបង្កើតឡើងក្រោយមករវាងភាគីជាប់កិច្ចសន្យា ដើម្បីបំពេញបន្ថែមលើកិច្ចព្រមព្រៀងបច្ចុប្បន្ន ហើយបានចែងនូវបទបញ្ញត្តិមានលក្ខណៈទូទៅឬពិសេស ផ្តល់សិទ្ធិដល់ការវិនិយោគដែលបានធ្វើឡើងដោយវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តកម្ម ដែលមានអំណោយផលជាងអ្វីដែលបានផ្តល់ដោយកិច្ចព្រមព្រៀងបច្ចុប្បន្ន បទបញ្ញត្តិដែលមានភាពអនុគ្រោះជាងនោះនឹងមានអនុភាពអនុវត្តលើកិច្ចព្រមព្រៀងបច្ចុប្បន្ន ។

មាត្រានី ១០

ដំណោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា និងវិនិយោគិន នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

១- វិវាទណាមួយដែលកើតឡើងដោយផ្ទាល់ពីសំណាក់ការវិនិយោគរវាងភាគីជាប់កិច្ចសន្យាមួយជាមួយវិនិយោគិននៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នឹងត្រូវដោះស្រាយដោយមិត្តភាពរវាងភាគីពាក់ព័ន្ធ ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយ(៦)ខែ ចាប់ពីថ្ងៃដែលករណីវិវាទត្រូវបានលើកឡើងជាលាយល័ក្ខអក្សរ វិវាទនោះនឹងត្រូវជ្រើសរើសដោយវិនិយោគិនដើម្បីស្នើបញ្ជូនទៅ :

ក- តុលាការមានសមត្ថកិច្ចនៃភាគីជាប់កិច្ចសន្យាក្នុងទឹកដីដែលការវិនិយោគបានធ្វើឡើងឬ

ខ- តុលាការអាជ្ញាកណ្តាល អាត់-ហុក ដែលជាតុលាការនឹងត្រូវបង្កើតឡើងក្រោមវិធានមជ្ឈត្តវិនិច្ឆ័យនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) លើកលែងតែមានការយល់ព្រមខុសពីនេះដោយភាគីវិវាទ ។ អាចជាករណីមិនមានការតវ៉ាជាស្វ័យប្រវត្តិទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិទេ លើកលែងតែភាគីជាប់កិច្ចសន្យា ឬភ្នាក់ងាររបស់ភាគីនោះ ឬអន្តរការីដែលមានការពាក់ព័ន្ធបានធ្វើការបញ្ជាក់ទៅក្នុងកិច្ចព្រមព្រៀងជាមួយវិនិយោគិន ។

៣- កិច្ចព្រមព្រៀងដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យាម្ខាងជាមួយវិនិយោគិន នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នឹងមានសិទ្ធិគ្របដណ្តប់កិច្ចព្រមព្រៀងនេះ និងវិធីនៃការដោះស្រាយជំលោះ

ប្រសិនបើមាន ដែលបានកំណត់ក្នុងនោះ នឹងតំរូវឱ្យភាគីទាំងពីរអនុវត្តដោយមិនគិតពីកិច្ចព្រមព្រៀងនេះឡើយ ។

៤- វិនិយោគិនដែលបានដាក់ជូនជំលោះទៅជូនតុលាការជាតិ មិនអាចមានសិទ្ធិប្តឹងតវ៉ាទៅតុលាការអាជ្ញាកណ្តាលណាមួយដូចមានបញ្ជាក់នៅក្នុងវាក្យខ័ណ្ឌ ២ (ខ) និង (៣) នៃមាត្រានេះទេ ។

៥- គ្មានភាគីជាប់កិច្ចសន្យាណាមួយដែលជាភាគីវិវាទអាចលើកឡើងនូវការជំទាស់ទៅតាមដំណាក់កាលណាមួយនៃនីតិវិធីមជ្ឈត្តវិនិច្ឆ័យឬការដាក់ឱ្យអនុវត្តនូវសេចក្តីសំរេចរបស់អាជ្ញាកណ្តាលបានទេដោយហេតុថា វិនិយោគិនដែលជាភាគីជំលោះម្ខាងទៀតបានទទួលនូវសំណងដែលអាចជាមួយផ្នែក ឬទាំងអស់នៃការខាតបង់របស់ខ្លួនអាស្រ័យដោយមានការទទួលធានារ៉ាប់រង ។

៦- ការសំរេចរបស់មជ្ឈត្តករគឺជាការសំរេចចុងក្រោយ ហើយដែលភាគីជំលោះទាំងពីរត្រូវតែគោរព ។ ការសំរេចនោះត្រូវបានអនុវត្តស្របទៅតាមច្បាប់ជាតិ ។

៧- នៅក្នុងវិវាទរវាងវិនិយោគិនជាមួយភាគីជាប់កិច្ចសន្យា ច្បាប់នៃភាគីជាប់កិច្ចសន្យានឹងគ្រប់គ្រងលើការដោះស្រាយវិវាទនោះ ។

៨- ច្បាប់ដែលដាក់កំហិតរបស់ប្រទេសម្ចាស់ផ្ទះ នឹងត្រូវអនុវត្តចំពោះរាល់ការតវ៉ា ឬសំណើដែលធ្វើឡើងដោយវិនិយោគិនដើម្បីដាក់ទៅមជ្ឈត្តវិនិច្ឆ័យលើកលែងតែកន្លែងណាដែលវិធាននៃច្បាប់មជ្ឈត្តវិនិច្ឆ័យពាក់ព័ន្ធនោះផ្តល់នូវរយៈពេលខ្លីនៃការកំណត់ខ័ណ្ឌសីមាដែលវិធានសំរាប់ករណីនោះ នឹងត្រូវអនុវត្តទៅបាន ។

មាត្រានី ១១
ការដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តន៏កិច្ចព្រមព្រៀងនេះនឹងត្រូវដោះស្រាយតាមការចរចារទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក្នុងរយៈពេលប្រាំមួយ (៦) ខែទេនោះ វិវាទនោះត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាណាមួយទៅតុលាការអាជ្ញាកណ្តាល ។

៣- តុលាការអាជ្ញាកណ្តាលនោះត្រូវបានបង្កើតឡើងទៅតាមករណី អាត់-ហុក តាមបែបបទដូចតទៅ : ភាគីជាប់កិច្ចសន្យានិមួយៗ ត្រូវតែងតាំងអាជ្ញាកណ្តាលរបស់ខ្លួនម្នាក់ទៅក្នុងតុលាការអាជ្ញាកណ្តាលនោះ បន្ទាប់មកអាជ្ញាកណ្តាលទាំងពីរនេះត្រូវជ្រើសរើសជនជាតិម្នាក់នៃរដ្ឋទី ៣ ដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល ។ អាជ្ញាកណ្តាលទាំងនេះ ត្រូវតែងតាំងអោយស្រេចក្នុងរយៈពេលពីរ (២) ខែ គិតពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីម្ខាងទៀត នូវគោលបំណងក្នុងការដាក់វិវាទនោះទៅតុលាការអាជ្ញាកណ្តាល ហើយប្រធានតុលាការអាជ្ញាកណ្តាលត្រូវបានតែងតាំងក្នុងរយៈពេលពីរ (២) ខែបន្ទាប់ ។

៤- ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ មិនអាចធ្វើបានបើគ្មានការសំរបសំរួលណាទៀតទេនោះ ភាគីជាប់កិច្ចសន្យាណាមួយអាចអញ្ជើញប្រធានតុលាការយុត្តិធម៌អន្តរជាតិដើម្បីធ្វើការតែងតាំងជាចាំបាច់នេះ ។ ប្រសិនបើប្រធានតុលាការនោះជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបាន អនុប្រធានតុលាការនឹងត្រូវបានតែងតាំងជាប្រធានតុលាការ ឬក្នុងករណីដែលអនុប្រធានមិនមានសមត្ថភាព សមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិដែលមានឋានៈ បន្ទាប់នឹងត្រូវបានអញ្ជើញ ដើម្បីធ្វើការតែងតាំងនេះដោយស្ថិតនៅក្រោមលក្ខខ័ណ្ឌដូចគ្នា ។

៥- តុលាការអាជ្ញាកណ្តាល ត្រូវកំណត់នូវនីតិវិធីការងារសំរាប់ដំណើរការរបស់ខ្លួន ។ ទីកន្លែងសំរាប់ដំណើរការមជ្ឈត្តវិនិច្ឆ័យ នឹងត្រូវកំណត់ដោយភាគីជាប់កិច្ចសន្យា ។

៦- តុលាការអាជ្ញាកណ្តាល ត្រូវធ្វើការសំរេចក្តីដោយយោងទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងផ្អែកទៅតាមវិធាននៃច្បាប់អន្តរជាតិ ។ ការសំរេចក្តីត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតយកសំឡេងភាគច្រើន ។ ការសំរេចក្តីនោះ គឺជាការសំរេចចុងក្រោយ ហើយដែលភាគីជំលោះត្រូវតែគោរពតាម ។

៧- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលរ៉ាប់រងចេញនូវសោហ៊ុយចំណាយសំរាប់អាជ្ញាកណ្តាលរបស់ខ្លួន និង សំរាប់អ្នកតំណាងស្របច្បាប់របស់ខ្លួន ក្នុងដំណើរការដំណោះស្រាយវិវាទរបស់អាជ្ញាកណ្តាល ។ តម្លៃចំណាយសំរាប់ប្រធានតុលាការ និងចំណាយដែលនៅសេសសល់ទៀត ត្រូវតែជាបន្ទុកដែលភាគីទាំងពីរត្រូវទទួលចេញដោយស្មើគ្នា ។ ទោះជាយ៉ាងណាក៏ដោយតុលាការអាចធ្វើការសំរេចក្តីឱ្យធ្វើការបែងចែកការចំណាយតាមរូបភាពផ្សេងទៀត ។

មាត្រាទី ១២

ការអនុវត្តនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្តសំរាប់ការវិនិយោគដែលធ្វើ មុន ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនអនុវត្តសំរាប់វិវាទវិនិយោគដែលបានកើតឡើងមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

មាត្រាទី ១៣

ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅថ្ងៃដែលទទួលបាននូវការជូនដំណឹងចុងក្រោយពីភាគីទាំងពីរតាមផ្លូវទូត ដោយភាគីជាប់កិច្ចសន្យាម្ខាងជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតថា តំរូវការផ្នែកច្បាប់ក្នុងប្រទេសសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងបានបំពេញរួចរាល់ហើយ ។

មាត្រាទី ១៤

រយៈពេល និងការបញ្ចប់

១- កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តរយៈពេលដប់ (១០)ឆ្នាំ ហើយត្រូវនៅបន្តមានសុពលភាពសំរាប់រយៈពេលដប់ (១០)ឆ្នាំទៀត លើកលែងតែមួយឆ្នាំមុនពេលផុតកំណត់នៃថិរវេលាដំបូង ឬរយៈពេលបន្តបន្ទាប់ ភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវគោលបំណងស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ ។ ក្នុងករណីនេះ សេចក្តីជូនដំណឹងពីការបញ្ចប់នឹងមានប្រសិទ្ធភាពចាប់ពីពេលផុតកំណត់នៃរយៈពេល ដប់ (១០) ឆ្នាំនេះ ។

២- ចំពោះការវិនិយោគដែលបានធ្វើមុនថ្ងៃ ការជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀងចូលជាធរមាន បណ្តាបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវស្ថិតនៅមានប្រសិទ្ធិភាព និងអនុវត្តបន្តសំរាប់រយៈពេល ដប់(១០)ឆ្នាំទៀត ដោយចាប់គិតពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ ។

ដើម្បីជាសក្ខីភាពកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាលរៀង១ខ្លួនមានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤ ចំនួនជា ២ ច្បាប់ដើម ជាភាសាខ្មែរ និងអង់គ្លេស ហើយអត្ថបទទាំងអស់មានតំលៃដូចគ្នា ។ ក្នុងករណីមានការបកស្រាយផ្សេងគ្នា អត្ថបទជាភាសាអង់គ្លេស ត្រូវបានយកជាសំអាង។

តំណាងរដ្ឋាភិបាលនៃ
ព្រះរាជាណាចក្រកម្ពុជា

ចម ប្រសិទ្ធ
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃ
សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

បណ្ឌិត អាប់ឌុល ហាហ្វីស ស្អែក
រដ្ឋមន្ត្រីឯកឧត្តមនាទូបនីយកម្ម

AGREEMENT BETWEEN THE GOVERNMENT OF THE KINGDOM OF CAMBODIA AND THE GOVERNMENT OF THE ISLAMIC REPUBLIC OF PAKISTAN ON THE PROMOTION AND PROTECTION OF INVESTMENT

The Government of the Kingdom of Cambodia and the Government of the Islamic Republic of Pakistan hereinafter referred to as the "Contracting Parties";

Desiring to create favorable condition for greater economic cooperation between them and in particular for investments by investors of one State in the territory of the other State based on the principles of equality and mutual benefit;

Recognizing that the encouragement and reciprocal protection of such investments will be conducive to stimulating business initiative and increasing prosperity in both States;

Agreeing that a stable framework for investment will maximize effective utilization of economic resources and foster economic prosperity;

Having resolved to conclude the Agreement on the Promotion and Reciprocal Protection of Investments;

Have agreed as follows:

ARTICLE 1
DEFINITIONS

For the purposes of this Agreement:

1. The term "investment" means;

   a) "the assets or money invested in connection with economic activities connected with business by an investor of one Contracting Party in the territory of the other Contracting Party for setting up, establishment or control of Industry, undertaking or establishment engaged in the production, distribution or processing of any goods or the development and extraction of such mineral resources and products as may be specified in this behalf by the Contracting Party."

   b) "The term "investment "does not include contracts to provide a service and the construction contracts. "

   c) "In case of contract (s) between the resident of one Party and the resident of the other party, the terms and conditions of the contract (s) signed between them will over-ride the clauses of this agreement and will be governed by the terms and conditions of that contract(s)."

   d) "The time bound contract (s) will not be treated as investment."

2. The term "returns" means monetary returns yielded by an investment including any profits, interest, capital gains, dividends, royalties or fees.

3. The term "Investor" means in respect of either Contracting Party:

   a) a natural person, a national of a Contracting Party who makes an investment in the territory of the other Contracting Party;

   b) a legal person incorporated, constituted or, otherwise duly organised in accordance with the laws and regulations of one Contracting Party, having its seat and performing real business activity in the territory of the same Contracting Party

and making an investment in the territory of the other Contracting Party.

4. The term "freely convertible currency" means any currency that is widely used to make payments for international transactions and widely traded in the principal international exchange markets.

5. The term "territory" means:

(a) in respect of the Kingdom of Cambodia, the territory over which the Kingdom of Cambodia has sovereignty or jurisdiction.

(b) in respect of the Islamic Republic of Pakistan, the territories as defined in Article 1 (2) of the Constitution of Islamic Republic of Pakistan.

ARTICLE 2
PROMOTION AND PROTECTION OF INVESTMENTS

1. Each Contracting Party shall encourage and create favourable conditions for investors of the other Contracting Party to make investments in its territory and shall admit such investments in accordance with its laws and regulations.

2. In order to encourage mutual investment flows, each Contracting Party shall endeavour to inform the other Contracting Party, at the request of that other Contracting Party, on the investment opportunities in its territory.

3. Each Contracting Party shall consider in good faith whenever necessary in accordance with its laws and regulations without delay the request for permits required in connection with the activities of consultants or experts engaged by investors of the other Contracting Party.

4. Each Contracting Party shall subject to its laws, regulations and procedures affecting the entry stay and work of natural persons, examine in good faith and give consideration to request of key personnel (nationals of the contracting parties) including top managerial and technical persons who are employed for the purposes of investments in its territory to enter, remain temporarily and work in its territory. Immediate family members (spouse and minor children) of such key personnel shall also be granted similar treatment with regard to the entry and temporary stay in the host Contracting Party.

ARTICLE 3
PROTECTION OF INVESTMENTS

1. Each Contracting Party shall extend in its territory full protection and security to investments and returns of investors of the other Contracting Party. Neither Contracting Party shall impair by arbitrary or discriminatory measures, the development, management, maintenance, use, enjoyment, expansion, sale and if it is the case, the liquidation of such investments. A Contracting Party shall observe any other obligation it may have entered into with regard to investments of investors of the other Contracting Party.

2. Investments or returns of investors of a Contracting Party in the territory of the other Contracting Party shall be accorded fair and equitable treatment in accordance with the laws and regulations of the latter Contracting Party and the provisions of this Agreement.

ARTICLE 4
NATIONAL TREATMENT AND MOST FAVOURED NATION TREATMENT

1. Each Contracting Party shall accord in its territory to investments and returns of investors of the other Contracting Party a treatment no less favourable than that which it accords to investments and returns of its own investors, or investments and returns of investors of any other third State, whichever is more favourable to the investors concerned.

2. Contracting Party shall accord in its territory to investors of the other Contracting Party, as regards management, maintenance, employment, use or disposal of their investment, a treatment which is no less favourable than that which it accords to the investors of any third State.

3. The provisions of paragraph 1 and 2 of this Article shall not be construed so as to oblige one Contracting Party to extend to the investors of the other Contracting Party the benefit of any treatment, preference or privilege, which may be extended by the former Contracting Party by virtue of:

a) any existing or future customs union or economic union, free trade area or similar international agreements to which either of the Contracting Party is or may become a party in the future;

b) any international agreement or arrangement, completely or partially related to taxation,

ARTICLE 5
EXPROPRIATION

1. A Contracting Party shall not expropriate or nationalise, directly or indirectly, an investment in its territory of an investor of the other Contracting Party or take any measure or measures having equivalent effect (hereinafter referred to as "expropriation") except:

a) for a purpose which is in the public interest;

b) on a non-discriminatory basis;

c) in accordance with due process of law; and

d) accompanied by payment of prompt, adequate and effective compensation.

2. Such compensation shall be paid without delay.

3. Such compensation shall be equivalent to the fair market value of the expropriated investment immediately before the expropriation occurred. The fair market value shall not reflect any change in value occurring because the expropriation had become publicly known earlier.

4. Such compensation shall be fully realizable and freely transferable.

5. An investor of a Contracting Party affected by the expropriation carried out by the other Contracting Party shall have the right to prompt review of its case including the valuation of its investments and the payment of compensation in accordance with the provisions of this Article by a judicial authority or other competent and independent authority of the latter Contracting Party.

ARTICLE 6
COMPENSATION FOR DAMAGE OR LOSS

1. When investments made by investors of either Contracting Party suffer loss or damage owing to war or other armed conflict, civil disturbances, revolution, riot or similar events in the territory of the other Contracting Party, they shall be accorded by the latter Contracting Party, treatment, as regards restitution, indemnification, compensation or any other settlement, not less favourable than that accorded by the latter Contracting Party to its own investors or to investors of any third State, whichever is more favourable to the investors concerned. However, the losses which are covered under normal business risks, will not qualify for payment of compensation on this account.

2. Without prejudice to paragraph 1 of this Article, investors of one Contracting Party who in any of the events referred to in that paragraph suffer damage or loss in the territory of the other Contracting Party resulting from:

a) requisitioning of their property or part thereof by its forces or authorities;

b) destruction of their property by its force or authorities, which was not caused in combat action or was not required by the necessity of the situation, shall be accorded a prompt restitution, and where applicable prompt, adequate and effective compensation for damage or loss, sustained during the period of requisitioning or as a result of destruction of the property. Resulting payments shall be made in freely convertible currency without delay.

ARTICLE 7
TRANSFERS

1. Each Contracting Party shall permit that all payments relating to an investment in its territory of an investor of the other Contracting Party may be freely transferred into and out of its territory without delay. Such transfers shall include in particular, though not exclusively:

a) the initial capital and additional amounts to maintain or increase an investment;

b) returns as defined in paragraph 2 of Article 1 of this Agreement;

c) payments made under contract including a loan agreement relating to the investment;

d) proceeds from the sale or liquidation of all or any part of investments;

e) payments of compensation under Articles 5, 6 and 8 of this Agreement;

f) payments arising out of the settlement of an investment dispute;

g) earnings and other remuneration of personnel engaged from abroad in connection with an investment in accordance with Article 2 of this Agreement.

2. Each Contracting Party shall ensure that the transfers under paragraph 1 of this Article are made in a freely convertible currency at the prevailing rate of exchange quoted by Authorised Dealers valid on the date of transfer in the territory of the Contracting Party in which the Investment is made.

3. Each Contracting Party shall ensure that the interest, if any, on the payments compensation delayed or not made after the date fixed for payment is calculated together with compensation for the period starting with the occurrence of events under Articles 5, 6 and 8 until the date of transfer of payment and payment will be effected in accordance with the provisions of paragraph 1 and 2 of this Article.

ARTICLE 8
SUBROGATION

If a Contracting Party or its designated agency makes a payment under an indemnity, guarantee or contract of insurance against non-commercial risks given in respect of an investment of an investor in the territory of the other Contracting Party, the latter Contracting Party shall recognize the assignment of any right or claim of such investor to the former Contracting Party or its designated agency and the right of the former Contracting Party or its designated agency to exercise by virtue of subrogation any such right and claim to the same extent as its predecessor in title.

ARTICLE 9
APPLICATION OF OTHER LEGAL PROVISIONS

If the provisions of law of either Contracting Party or international obligations existing at present or established thereafter between the Contracting Parties, in addition to the present Agreement, contain a rule, whether general or specific, entitling investments by investors of the other Contracting Party to a treatment more favourable than is provided for by the present Agreement, such rule shall, to the extent that, it is more favourable, prevail over the present Agreement.

ARTICLE 10
SETTLEMENT OF DISPUTES BETWEEN A CONTRACTING PARTY AND AN INVESTOR OF THE OTHER CONTRACTING PARTY

1. Any investment dispute arising directly from an investment between one Contracting Party and an investor of the other Contracting Party should be settled amicably between the two parties concerned.

2. If a dispute has not been settled within six (6) months from the date on which it was raised in writing, the dispute may, at the choice of investor, be submitted:

a) to the competent courts of the Contracting Party in whose territory the investment is made; or

b) to any ad hoc arbitration tribunal which unless otherwise agreed on by the parties to the dispute, is to be established under the Arbitration Rules of the United Nations Commission on International Trade Law (UNCITRAL), provided that there can be no automatic recourse to such international arbitration unless the Contracting Party or its agency or its instrumentality concerned specification in its agreement with an investor.

3. An Agreement to settle the dispute between one Contracting Party and an investor of the other Contracting Party will override this Agreement and the mode of dispute settlement, if any, provided therein shall bind the Parties irrespective of this Agreement.

4. An investor who has submitted the dispute to a national court cannot have recourse to one of the arbitral tribunals mentioned in paragraph 2(b) and (3) of this Article.

5. Neither of the Contracting Party, which is a party to a dispute can raise an objection, at any phase of the arbitration procedure or of the execution of an arbitral award, on account of the fact that the investor, which is the other party to the dispute, has received an indemnification covering a part or the whole of its losses by virtue of an insurance.

6. The award shall be final and binding on the parties to the dispute and shall be enforced in accordance with national law.

7. In dispute between an investor and a Contracting Party, the law of the Contracting Party will govern the resolution of such disputes.

8. The law of limitation of the host country will be applicable to any claim or request made for arbitration by the investor except where the relevant arbitration rules provide for a shorter period of limitation in which case those rules will apply.

ARTICLE 11
SETTLEMENT OF DISPUTES BETWEEN THE CONTRACTING PARTIES

1. Disputes between the Contracting Parties concerning the interpretation or application of this Agreement shall be settled as far as possible by negotiations.

2. If a dispute cannot be settled under paragraph 1 of this Article within six (6) months, it shall upon the request of either Contracting Party be submitted to an arbitral tribunal.

3. Such arbitral tribunal shall be constituted ad hoc as follows: each Contracting Party shall appoint one arbitrator and these two arbitrators shall agree upon a national of a third State as their chairman. Such arbitrators shall be appointed within two (2) months from the date one Contracting Party has informed the other Contracting Party of its intention to submit the dispute to an arbitral tribunal, the Chairman of which shall be appointed within two (2) further months.

4. If the periods specified in paragraph 3 of this Article are not observed, either Contracting Party may, in the absence of any other relevant arrangement, invite the President of the International Court of Justice to make the necessary appointments. If the president of the International Court of Justice is a national of either of the Contracting Parties, or if he is otherwise prevented from discharging the said function, the Vice-President or in case of his inability, the member of the International Court of Justice next in seniority shall be invited under the same conditions to make the necessary appointments.

5. The arbitral tribunal shall determine its own procedure. The place of arbitration proceedings shall be determined by the Contracting Parties.

6. The arbitral tribunal shall make its award in accordance with the provision of this Agreement and pursuant to the rules of international law. It shall make its award by a majority of votes. The award shall be final and binding.

7. Each Contracting Party shall bear the costs of its own arbitrator and of its legal representation in the arbitration proceedings. The costs of the Chairman and the remaining costs shall be borne in equal parts by both Contracting Parties. The tribunal may, however, in its award determine another distribution of costs.

ARTICLE 12
APPLICATION OF THE AGREEMENT

This Agreement shall apply to investments made prior to or after the entry into force of this Agreement, but shall not apply to any investment dispute that may have arisen before its entry into force.

ARTICLE 13
ENTRY INTO FORCE

This Agreement shall enter into force on the date of receipt of the last of the two notifications through diplomatic channels by which either Contracting Party notifies the other Contracting Party that its internal legal requirements for the entry into force of this Agreement have been fulfilled.

ARTICLE 14
DURATION AND TERMINATION

1. This Agreement shall remain in force for a period of ten (10) years and shall be extended thereafter for the following ten (10) year periods unless, one year before the expiration of the initial or any subsequent period, one Contracting Party notifies the other Contracting Party of its intention to denounce the Agreement. In that case, the notice of denunciation shall become effective by the expiration of the current period of ten (10) years.

2. In respect of investments made prior to the date when the notice of termination of this Agreement become effective the provisions of this Agreement shall continue to be effective and applicable for a period of ten (10) years from the date of termination of this Agreement.

IN WITNESS WHEREOF, the undersigned representatives, duly authorised thereto, have signed the present Agreement.

DONE at Phnom Penh, on 27th April 2004, in two originals, each in the Khmer, and English languages, all texts being equally authentic. The text in the English language shall prevail in case of difference of interpretation.

FOR THE GOVERNMENT OF THE KINGDOM OF CAMBODIA	**FOR THE GOVERNMENT OF THE ISLAMIC REPUBLIC OF PAKISTAN**
CHAM PRASIDH Minister of Commerce	**Dr. ABDUL HAFEEZ SHEIKH** Minister of Privatisation

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៤៩៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិ**ឧត្តមមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ គិតចាប់ពីថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៧ ជូនមន្ត្រីរាជការ **ចំនួន ១៤ រូប** ដូចមានរាយនាមខាងក្រោម :

១ -	ឯកឧត្តម **ស្លា ប្រយុទ្ធ**	ឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ១
២ -	ឯកឧត្តម **ម៉េង គីមលី**	ឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ១
៣ -	ឯកឧត្តម **ខូយ ឃុនហួរ**	ឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ១
៤ -	ឯកឧត្តម **អ៊ុង អឿន**	ឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ២
៥ -	ឯកឧត្តម **ខៀវ ជា**	ឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ២
៦ -	ឯកឧត្តម **កៅ ខុនជាអ៊ា**	ឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ២
៧ -	លោកជំទាវ **សុខ សំណាង**	ឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ២
៨ -	ឯកឧត្តម **ជួង ស៊ីវុទ្ធ**	ឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣
៩ -	លោកជំទាវ **ផេង គីម**	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤

ROYAUME DU CAMBODGE
MINISTÈRE ... ROYAL

១០-	ឯកឧត្តម ទ៉ាន់ ទុច	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
១១ -	ឯកឧត្តម គោគ សំអេន	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
១២ -	ឯកឧត្តម គ្រាក់ ថៃសៀង	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
១៣ -	ឯកឧត្តម ប៉ិច សុខិន	ឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤
១៤ -	ឯកឧត្តម កុល ធីរក្ស	ឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរក.០៧១០.៥២២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៧

លេខៈ ៤៧៩ ចប.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ១០ ឆ្នាំ ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

មុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៤៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១- ឯកឧត្តម ចិន គ្រាំឈៃ ជាទីប្រឹក្សាឯកឧត្តម ចិន ឈិន ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ។

២- ឯកឧត្តម ចិន ចិន្តនាត ជាជំនួយការឯកឧត្តម ចិន ឈិន ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.ល.០៧១០.៥២៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៧

ដើម្បីចម្លងចែក
ឆ្នាំ២០០៧

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៥០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋាន
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣***៥

ក្រសួងសាធារណការ និងដឹកជញ្ជូន

ភ្ជាប់ឧបសម្ព័ន្ធប្រកាសលេខ ...៧២៧.ប្រក.សក.បផ ចុះថ្ងៃទី ..១៥.....ខែ តុលា ឆ្នាំ ២០០៧

រចនាសម្ព័ន្ធ មជ្ឈមណ្ឌលគ្រឿងចក្រធំៗ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបុរីជលសា និង ស្រុកកោះអណ្តែត ខេត្តតាកែវ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៧

ស ម្រេ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅបង្កើតតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបូរីជលសា និងស្រុកកោះអណ្តែត ខេត្តតាកែវ ។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលបំណង ៖

- ការពារ អភិរក្សសត្វក្រៀល សត្វស្លាបផ្សេងទៀត មច្ឆជាតិ និង ធនធានសេនេទិច រុក្ខជាតិ ពិសេសប្រភេទជិតផុតពូជ និង ប្រភេទដែលកំពុងទទួលរងគ្រោះ ព្រមទាំងរក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ និង ទីជម្រករបស់វា

- ការពារ និង ថែរក្សាប្រភពទឹក ឱ្យមានប្រក្រតីភាពសម្រាប់ជីវៈចម្រុះ និង ការស្រោចស្រពក្នុងវិស័យកសិកម្ម ព្រមទាំងទ្រទ្រង់ឱ្យមានការអភិវឌ្ឍ ដែលធានាឱ្យមាននិរន្តរភាពតំបន់អេកូឡូស៊ី សេដ្ឋកិច្ចសង្គម និង ជីវភាពរស់នៅ

- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល អភិវឌ្ឍសហគមន៍ ការអង្កេតតាមដានពីភាពប្រែប្រួលបរិស្ថាន ដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការអភិរក្សនៅក្នុងកម្រិតមូលដ្ឋាន កម្រិតជាតិ និង កម្រិតតំបន់ ។

ជំពូកទី ២
ការកំណត់តំបន់

មាត្រា ៣.-

តំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត មានផ្ទៃក្រឡាទំហំ **៨.៣០៥** ហិកតា (ប្រាំបីពាន់បីរយប្រាំហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា : **A** (498049, 1192141); **B** (497888, 1183698); **C** (497895, 1182741); **D** (504063, 1182737); **E** (508012, 1185033); **F** (508001, 1188152); **G** (507635, 1188401); **H** (507607, 1189159); **I** (507626, 1189899); **J** (507620, 1189975); **K** (506012, 1189966); **L** (505992, 1191709) ។

មាត្រា ៤.-

ផ្ទៃក្រឡាតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ដែលកំណត់ក្នុងមាត្រា៣ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និង ស្ថានភាពជាក់ស្តែងនាពេលអនាគត ។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៣
ការចាត់ថ្នាក់ និង ការគ្រប់គ្រង

មាត្រា ៥.-

តំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបូរីជលសា និង ស្រុកកោះអណ្តែត ខេត្តតាកែវ ត្រូវបានបែងចែកជាពីរតំបន់គឺ តំបន់ស្នូល និង តំបន់ទ្រនាប់ ដែលមានព្រំប្រទល់ដូចខាងក្រោម ÷

១-តំបន់ស្នូល មានទីតាំងស្ថិតនៅក្នុងឃុំកំពង់ក្រសាំង ឃុំជ័យជោគ ស្រុកបូរីជលសា និង ឃុំព្រៃខ្លា ឃុំក្រពុំឈូក ស្រុកកោះអណ្តែត មានផ្ទៃក្រឡាទំហំ **៥១៥** ហិកតា (ប្រាំបួនរយដប់ប្រាំបួនហិកតា) ដូចមានផែនទីភ្ជាប់ ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា : **a** (501481, 1188861); **b** (501537, 1186000); **c** (504741, 1186000); **d** (504722, 1188861) ។

២-តំបន់ទ្រនាប់ មានទីតាំងព័ទ្ធជុំវិញតំបន់ស្នូលស្ថិតនៅក្នុងឃុំកំពង់ក្រសាំង និង ឃុំជ័យជោគ ស្រុកបូរីជលសា និង ឃុំព្រៃខ្លា ឃុំក្រពុំឈូក ឃុំព្រៃយុថ្កា ឃុំរមេញ ស្រុកកោះអណ្តែត ។

មាត្រា ៦.-

តំបន់ស្នូលជាតំបន់ មានសារប្រយោជន៍ សម្រាប់ការពារ និង អភិរក្សធនធានធម្មជាតិ យ៉ាងហ្មត់ចត់ ដើម្បីថែរក្សាឱ្យបានគង់វង្ស នូវព្រៃលិចទឹក មច្ឆជាតិ ប្រភពចំណីអាហារសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ។ តំបន់ស្នូលអនុញ្ញាតឱ្យ មានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រ ការអង្កេតតាមដាន បម្រើសេវាកម្មទេសចរណ៍ធម្មជាតិ និង ការនេសាទត្រី ប្រកបដោយនិរន្តរភាព ដោយមិនអនុញ្ញាតឱ្យមាន សកម្មភាពប្រើប្រាស់ ដែលធ្វើឱ្យរេចរឹល ឬ បំផ្លាញដល់ជីវៈចម្រុះឡើយ ។

តំបន់ទ្រនាប់ជាតំបន់ដែលគ្របដណ្តប់ ដោយវាលស្មៅដីសើម ជាតំបន់សម្រាប់បម្រើវិស័យកសិកម្ម ដឹកជញ្ជូនទំនិញឆ្លងកាត់ និង អភិវឌ្ឍន៍ផ្សេងៗ ដោយធានានិរន្តរភាពនៃធនធានមច្ឆជាតិ ប្រភពធនធានទឹក និង ជម្រកសត្វក្រៀល និង សត្វស្លាបផ្សេងទៀតក្នុងតំបន់នោះ ។

មាត្រា ៧.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទមានសមត្ថកិច្ចរៀបចំ និង គ្រប់គ្រងតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និង អាជ្ញាធរមូលដ្ឋាន ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព សម្រាប់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ដំណើរការនៃការរៀបចំ និង គ្រប់គ្រងតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និង សត្វស្លាបផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់វិទ្យាស្ថានច្រាយហ្វូម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៤០៣៣ អយក.ឧស. ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧

សម្រេច

មាត្រា ១ : ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានប្រាយហូប** (**Bright Hope Institute**) សរសេរកាត់ជាភាសាខ្មែរ **វ.ប.ហ** និងសរសេរកាត់ជាភាសាអង់គ្លេស " **B.H.I** "។

មាត្រា ២ : វិទ្យាស្ថានប្រាយហូប មានទីតាំងស្ថិតនៅ ភូមិម៉ុងបារាំង ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៣ : វិទ្យាស្ថានប្រាយហូប ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ។ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ (ប្រាំមួយ) ខែ។

មាត្រា ៤ : វិទ្យាស្ថានប្រាយហូប មាន ពីរមហាវិទ្យាល័យ :

- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យ កសិកម្ម និងអភិវឌ្ឍជនបទ

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ ប្រភេទបណ្តុះបណ្តាលដទៃទៀត ឬប្តូរទីតាំងថ្មី ដោយរៀបចំសំណើ បែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : វិទ្យាស្ថានប្រាយហូប មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានប្រាយហូប ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៦ : នាយកវិទ្យាស្ថាន មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាននេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម។
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្របតាមការណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។
- គោរពតាមកិច្ចសន្យាដែលវិទ្យាស្ថានប្រាយហូប នៅខេត្តកំពង់ឆ្នាំង បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា។
- ធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

មាត្រា ៧ : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានប្រាយហូប និងទទួលបានជោគជ័យ ក្នុងការប្រឡង

ឱ្យដោយវិទ្យាស្ថានប្រាយហ្វូប ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានប្រាយហ្វូប បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានប្រាយហ្វូប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ១៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តកំពង់ឆ្នាំង
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :.១៥៧...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម
ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឃ

សំរេច

មាត្រា១: ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៣០.០០០ លានរៀល (សាមសិបពាន់លានរៀលគត់) ទៅលើសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ឥណទានថវិកាបន្ថែមដូចក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦១ (សេវាខាងក្រៅ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយលើការងារជួសជុល និង ថែទាំបេះដូងរចនាសម្ព័ន្ធជារូបវ័ន្ត របស់រាជរដ្ឋាភិបាល ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៤: ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខកាលបើការបោះអាណត្តិ ទូទាត់ចំណាយលើការងារជួសជុល និង ថែទាំបេះដូងរចនាសម្ព័ន្ធជារូបវ័ន្តរបស់រាជរដ្ឋាភិបាល ត្រូវបានចប់សព្វគ្រប់ ។

មាត្រា៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

lu

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.០០០ លានរៀល (ពីរពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចូលរួមចំណែកឧបត្ថម្ភកាកបាទក្រហមកម្ពុជា ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស /រកម / ១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាស លេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.២០០.០០០.០០០ រៀល (មួយពាន់ពីររយលានរៀលគត់) ពីជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) មកជំពូក ៦១ (សេវាខាងក្រៅ) ជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញបន្ថែមខ្ទង់មាតិកាចំណាយលើការថែទាំជួសជុលអាគារ និងប្រាសាទ ដើម្បីអនុវត្តគំរោងសាងសង់មជ្ឈមណ្ឌល សង្គមកិច្ចខេត្តសៀមរាប ឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ពិនិត្យចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ....៩១៩...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្របក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្របក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការដំឡើងឋានៈ និង ប្តូរឈ្មោះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្របក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការដំឡើងឋានៈ និង ប្តូរឈ្មោះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបាត់ដំបង ទៅជាវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំង :

១- លោក **អ៊ុក ដាវ៉ាន់នី** ជានាយកវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង មានឋានៈស្មើប្រធាននាយកដ្ឋាន

២-លោកស្រី **ជួន វ៉ាន់ឆេត** ជានាយិកាវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង មានឋានៈស្មើប្រធាននាយកដ្ឋាន

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឡាយ សំអួន** អោយបំពេញមុខងារ ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៧២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលថ្នាក់ និង តម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានកែសម្រួលថ្នាក់ក្នុង **ឋានន្តរស័ក្តិ វរមន្ត្រី** ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ **ចំនួន ០៤ រូប** ដូចមានរាយនាមខាងក្រោម :

១- លោក **ខៃ ឆាយឈាង** ពី វរមន្ត្រី ថ្នាក់លេខ ៨ ទៅជា វរមន្ត្រី ថ្នាក់លេខ ៣

២- លោក **ម៉េង សួន** ពី វរមន្ត្រី ថ្នាក់លេខ ៩ ទៅជា វរមន្ត្រី ថ្នាក់លេខ ៤

៣- លោក **សុខ រីហ៊ួរ** ពី វរមន្ត្រី ថ្នាក់លេខ ៩ ទៅជា វរមន្ត្រី ថ្នាក់លេខ ៤

៤- លោក **សេង យូរ៉ាន់** ពី វរមន្ត្រី ថ្នាក់លេខ ១០ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧

មាត្រា ២ : ត្រូវបានតម្លើង **ឋានន្តរស័ក្តិ** ពី **អនុមន្ត្រី** ទៅ **វរមន្ត្រី** ក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ **ចំនួន ២៨ រូប** ដូចមានរាយនាមខាងក្រោម :

១-លោក **តូច ញឹម** ពី អនុមន្ត្រី ថ្នាក់លេខ ៣ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦

២-លោក **ទិត សុខ** ពី អនុមន្ត្រី ថ្នាក់លេខ ៣ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦

៣-លោក **កុល សំអុល** ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦

៤-លោក ម៉ុន ហោ	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
៥-លោក ម៉ូ សាខន	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
៦-លោក នួន សុមេធ	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
៧-លោក ម៉ើន សំបូរ	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
៨-លោក ថុន ណារុល	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
៩-លោក ជិន លី	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
១០-លោក ម៉ាន់ ហាំ	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
១១-លោក ថី កេង	ពី អនុមន្ត្រី ថ្នាក់លេខ ៤ ទៅជា វរមន្ត្រី ថ្នាក់លេខ ៦
១២-លោក កែវ សែន	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៣-លោក គាវ សុវណ្ណធី	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៤-លោក រាជ សុភ័ន្ទ	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៥-លោក ហុង ស៊ីលីន	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៦-លោក អ៊ុន ឆាលី	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៧-លោក ស៊ីម សុវណ្ណី	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៨-លោក គឹម ឈាន	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
១៩-លោក ម៉ុន ថារឬទ្ធិ	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២០-លោក លន់ លីមថៃ	ពី អនុមន្ត្រី ថ្នាក់លេខ ៥ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២១-លោក សាមុត ធឿន	ពី អនុមន្ត្រី ថ្នាក់លេខ ៦ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២២-លោក អ៊ុំ សារឿន	ពី អនុមន្ត្រី ថ្នាក់លេខ ៦ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២៣-លោក សំ សំអាត	ពី អនុមន្ត្រី ថ្នាក់លេខ ៦ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២៤-លោក យស ណារ៉ុស៊ី	ពី អនុមន្ត្រី ថ្នាក់លេខ ៦ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២៥-លោក ឯក ម៉ី	ពី អនុមន្ត្រី ថ្នាក់លេខ ៦ ទៅជា វរមន្ត្រី ថ្នាក់លេខ ៧
២៦-លោក ម៉ូ ឡាំ	ពី អនុមន្ត្រី ថ្នាក់លេខ ៧ ទៅជា វរមន្ត្រី ថ្នាក់លេខ ៨
២៧-លោក ស្វាយ សំអ៊ាង	ពី អនុមន្ត្រី ថ្នាក់លេខ ៩ ទៅជា វរមន្ត្រី ថ្នាក់លេខ ១០
២៨-លោក សរ សិទ្ធិ	ពី អនុមន្ត្រី ថ្នាក់លេខ ១០ទៅជា វរមន្ត្រី ថ្នាក់លេខ ១០

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **ដាក់គ្លីស ហ្គាដណឺ** (Douglas Gardner) ជាអ្នកសម្របសម្រួល អង្គការសហប្រជាជាតិ និងជាប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំប្រទេសកម្ពុជា ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងកិច្ចអភិវឌ្ឍន៍របស់កម្ពុជា ជាពិសេស បានជួយឧបត្ថម្ភគាំទ្រដល់ព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញកិច្ចសហការអនុវត្ត អោយបានសម្រេចនូវកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងកម្មវិធីសេដ្ឋកិច្ច សង្គមជាច្រើនទៀត រួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៧

សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥២៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១: ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី យឹម ចាន់ស្រី ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានអប់រំកុមារតូច នៃក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧២៤-អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **អ៊ុំ គឹមសុខ** អត្តលេខ ០៦៣៥

២- លោកវរសេនីយ៍ទោ **ឃីម សុវណ្ណ** អត្តលេខ ០៦៤៤

៣- លោកវរសេនីយ៍ទោ **ចាន់ សុរិយា** អត្តលេខ ០៧៩៤

៤- លោកវរសេនីយ៍ទោ **អោក សំណាង** អត្តលេខ ០៧៩៥

៥- លោកវរសេនីយ៍ទោ **ស ខេង** អត្តលេខ ០១០៩៦

៦- លោកវរសេនីយ៍ទោ **ប៊ុម មីន** អត្តលេខ ០១៧៤៤

៧- លោកវរសេនីយ៍ទោ **រ័ត្ន ឈូ** អត្តលេខ ០៧២២៥

៨- លោកវរសេនីយ៍ទោ **តោក សុខុន** អត្តលេខ ០១៨៣៧

៩- លោកវរសេនីយ៍ទោ **អ៊ុក សារ៉ាយ** អត្តលេខ ២០៤៣១.

១០- លោកវរសេនីយ៍ទោ **ឈឿង គិមឃ្យ** អត្តលេខ ៥៨៧០៨ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១២២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់ប័ណ្ណស្ថាបនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៤ រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់ខ្លួន ជួយកសាងខ្លោងទ្វារ កុដិ សាលាឆាន់ នៅវត្តក្រសាំងជ្រៃ ជួយកសាងសាលាបឋមសិក្សាក្រសាំងជ្រៃ ផ្លូវ អណ្តូងទឹក និងសមិទ្ធិផលនានាជាច្រើន ស្ថិតនៅក្នុងឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ :

ក_ មេដាយមាសស្ថាបនាជាតិ :

១-ឯកឧត្តម **ស៊ំ ចន្ទ្រាខន**	អគ្គលេខាធិការក្រសួងការពារជាតិ	ថវិកាចំនួន	១៩.៩៣៩ ដុល្លារ
២-លោកជំទាវ **ទី សុជាតិ**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	១៤.៤៨១ ដុល្លារ

ខ_ មេដាយប្រាក់ស្ថាបនាជាតិ :

១-ព្រះតេជគុណ **អ៊ុន ឃន**	ចៅអធិការវត្តក្រសាំងជ្រៃ	បច្ច័យចំនួន	៩.២៩៥ ដុល្លារ
២-ឧបាសិកា **ងាត់ ឡាំង**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៦.៤៣៥ ដុល្លារ

គ. មេដាយសេរីវឌ្ឍិស្ថាបនាជាតិ :

១-ឧបាសក ជូ ឆាយ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២.៥៩៨ ដុល្លារ
២-លោក ខ្យូ សុវណ្ណា សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១.៣៤៦ ដុល្លារ
៣-លោក ហ៊ុយ ឌី សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១.១៧២ ដុល្លារ
៤-ឯកឧត្តម ពេជ្រ ឈឿន សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១.១០០ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
  អគ្គលេខាធិការរាជរដ្ឋាភិបាល
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៤៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

១០៩

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ ៈ ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសមាជិក សមាជិកា ក្រុមប្រឹក្សាភិបាលសភាមុខរបរ និង មិត្តភ្រូសហគ្រាសកម្ពុជា ចំនួន១៥ រូប ដែលបានស្ម័គ្រចិត្តចូលរួមវិភាគទានជាថវិកាផ្ទាល់ខ្លួន ជួយទ្រទ្រង់ដល់ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាមុខរបរ និងមិត្តភ្រូសហគ្រាសកម្ពុជា ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម ៈ-

ក. មេដាយមាសស្ថាបនាជាតិ ៈ

១- ឧកញ៉ា	ស៊ិន	សុខណា	ថវិកា ចំនួន ១១.០០០ ដុល្លារ
២- ឧកញ៉ា	អាន	ម៉ាឌី	ថវិកា ចំនួន ១១.០០០ ដុល្លារ
៣- ឧកញ៉ា	ហាន់	ឃៀង	ថវិកា ចំនួន ១១.០០០ ដុល្លារ
៤- ឧកញ៉ា	ឡាយ	ម៉ុនជា	ថវិកា ចំនួន ១១.០០០ ដុល្លារ
៥- ឧកញ៉ា	លឹម	ម៉ុនសួរ	ថវិកា ចំនួន ១១.០០០ ដុល្លារ
៦- ឧកញ៉ា	ឡេង	មូរ៉ាឌី	ថវិកា ចំនួន ១១.០០០ ដុល្លារ
៧-លោក	ហ៊ិន	ឡាក់	ថវិកា ចំនួន ១១.០០០ ដុល្លារ
៨-ឧកញ៉ា	សូ	ខូន	ថវិកា ចំនួន ១០.០០០ ដុល្លារ
៩-ឧកញ៉ា	ង៉ែ	ហុកឈួន	ថវិកា ចំនួន ១០.០០០ ដុល្លារ
១០-លោក	ហាក់	ម៉ុនថា	ថវិកា ចំនួន ១០.០០០ ដុល្លារ
១១-លោក	ហ៊ុន	ចន្ថា	ថវិកា ចំនួន ១០.០០០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

- ឧកញ៉ា	**ចាន់ សុខ្ជា**	ថវិកា ចំនួន ៥.០០០ ដុល្លារ

គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-ឯកឧត្តម	**សុន គន្ធរ**	ថវិកា ចំនួន ២.០០០ ដុល្លារ
២-លោក	**ឈរ ម៉ារិទ្ធ**	ថវិកា ចំនួន ១.០០០ ដុល្លារ
៣-លោក	**ហួត ស្រេងគីម**	ថវិកា ចំនួន ១.០០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានក្រុមប្រឹក្សាភិបាលសភាមុខរបរ និង មីក្រូសហគ្រាសកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៧

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តពោធិ៍សាត់

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **នៅ សុគន្ធថៃ** ព្រះចៅអធិការវត្ត ហង្សាបីតិ ហៅ វត្តព្រៃកស្ទី ដែលមានស្នាព្រះហស្ត និងគុណបំណាច់ធំៗជាច្រើនក្នុងការចលនាសប្បុរសជនក្នុង និងក្រៅប្រទេស ជួយកសាងសមិទ្ធផលនានា សំរាប់សង្គម និងព្រះពុទ្ធសាសនា ព្រមទាំងឧបត្ថម្ភដល់ប្រជាពលរដ្ឋក្រីក្រ និងកុមារកំព្រា រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅក្នុងឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ដោយចំណាយអស់បច្ច័យ សរុបចំនួន ១៣៩.៩១២,៣៧ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសាលាពុទ្ធិកបឋមសិក្សា ០១ខ្នង មាន០៦បន្ទប់ ខ្លោងទ្វារ ០២ និង របង ប្រវែង ១០០ម៉ែត្រ នៅវត្តកំពូលមាស ហៅ វត្តប្រឡាយ ក្នុងឃុំកណ្តោល ស្រុកកំពត ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

១-លោក **មួញ ឡុន** សប្បុរសជន នៅក្រុងព្រះសីហនុ ថវិកាចំនួន ១៣.០០០ ដុល្លារ

២-លោក **ជាវ ហុងសេង** សប្បុរសជន នៅក្រុងភ្នំពេញ ថវិកាចំនួន ១២.០០០ ដុល្លារ

៣-អ្នកស្រី **អ៊ឹង សុខនៀង** សប្បុរសជន នៅក្រុងភ្នំពេញ ថវិកាចំនួន ១១.៥៥០ ដុល្លារ

៤-លោក **អ៊ី គានអាង** សប្បុរសជន នៅ ខេត្តកំពត ថវិកាចំនួន ១១.០៨០ ដុល្លារ

៥-លោក **រស់ ឫទ្ធី** សប្បុរសជន នៅក្រុងព្រះសីហនុ ថវិកាចំនួន ១១.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែរ រស់នៅសហរដ្ឋអាមេរិក ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងកុដិថ្មពីរជាន់ បង្គន់អនាម័យ និងរោងប្រពៃណី នៅវត្តកែវឧត្តម ឃុំសង្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម :-

១-ឧបាសិកា **កែ ឡុង** ថវិកា ចំនួន ១០.៣៥០ ដុល្លារ

២-លោក **កែ ទូចឈាង** ថវិកា ចំនួន ១០.៣៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សរិទ្ធិ** ជូនលោក **ទេព ថុន្នារ** ប្រធាននាយកដ្ឋានឧស្សាហកម្ម និងសំណង់ ដែលមានអតីតភាពការងារជាច្រើនឆ្នាំ ហើយមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនទីស្តីការគណៈរដ្ឋមន្ត្រី តាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបាន[illegible] ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ ដូចជាព្រះវិហារជាដើម នៅវត្តអង្គពោធិ ក្នុងឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ដូចមានព្រះនាមនិងនាមខាងក្រោម :-

១-ព្រះភិក្ខុ **សាយ កែវ** ចៅអធិការវត្តអង្គពោធិ បច្ច័យ ចំនួន ៥៥.៤៦៣,០៣ ដុល្លារ

២-លោក **វ៉ាំ សេងណាំ** ប្រធានក្រុមហ៊ុនទឹកបរិសុទ្ធ ពន្លឺឧត្តមនៅក្រុងភ្នំពេញ ថវិកា ចំនួន ១៦.៩៤៤ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ[illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគថវិកា ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៣បន្ទប់ បំពាក់ដោយសម្ភារីមសិក្សាគ្រប់គ្រាន់ ធ្វើរបង និងចាក់ដីបំពេញទីធ្លា នៅសាលាបឋមសិក្សាបារគូ ស្ថិតក្នុងឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាម ខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-អ្នកស្រី	ELYSABETH UPDIKA	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.៥០០ ដុល្លារ
២-ឧកញ៉ា	SAMBONN LEK	ប្រធានអង្គការសង្គ្រោះ	ថវិកាចំនួន ១០.៣០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-លោក **គង់ ចំនួថា**	អនុប្រធានអង្គការសង្គ្រោះ	ថវិកាចំនួន ៦.១០០ ដុល្លារ

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣៣ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគដីនិងថវិកា ក្នុងការជួយសាងសង់អគារសិក្សា ជូនដល់អនុវិទ្យាល័យ **ហ៊ុន សែន ប៊ុន រ៉ានី អរុណវតី** ស្ថិតនៅរាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ **សំ ខួន** ព្រះចៅអធិការវត្តអរុណវតី បានឧបត្ថម្ភដី ទំហំ ៨.៨៨០ ម៉ែត្រការេ គិតជាទឹកប្រាក់មានចំនួន ២៦.៦៤០ ដុល្លារអាមេរិក ។

២-លោកឧកញ៉ា **ដួខ ទៀប** ប្រធានក្រុមហ៊ុន DNG GROUP បានផ្ដល់ថវិកា ចំនួន ៩០.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង ០២ជាន់ មាន១០បន្ទប់ ។

៣-លោកជំទាវ **ខុច ឈីស៊ីអាណា** បានផ្ដល់ថវិកាចំនួន ៩០.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង ០២ជាន់ មាន ១០បន្ទប់ ។

៤-លោក **ឈួន សុភាខ** នាយកអនុវិទ្យាល័យ **ហ៊ុន សែន ប៊ុន រ៉ានី អរុណវតី**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលរាជធានី ភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកា ចំនួន ៥១.៧១៨ ដុល្លារអាមេរិក ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ផ្គត់ផ្គង់សំភារៈបណ្ណាល័យ ផ្តល់ទូរភ័ណ្ឌនិកេតតាមថ្នាក់ រៀបចំបណ្តាញទឹក និងសំភារៈឧបទ្ទេស ជូនដល់សាលាបឋមសិក្សាព្រែកប្រាក្រោម ស្ថិតនៅខណ្ឌមានជ័យ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី AMBRA ENRICO អគ្គលេខាធិការអង្គការ CIFA

២-លោក **ខ៊ូច ឈឺទ** នាយកអង្គការ CIFA

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ... ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០២រូប ដែលបានឧបត្ថម្ភថវិកាជួយកសាងសាលាបឋមសិក្សា និង អនុវិទ្យាល័យចតុមុខ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយប្រាក់ស្ថាបនាជាតិ :

-លោក **សូត្រ សុមុនី** ឧបត្ថម្ភថវិកា ចំនួន ៦.០០០ ដុល្លារអាមេរិក ជួយកសាង ខ្លោងទ្វារ នៅច្រកទ្វារខាងលិច នៃអនុវិទ្យាល័យចតុមុខ ។

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :

-ឯកឧត្តម **ស្រី សុមិន្ត** ឧបត្ថម្ភថវិកា ចំនួន ៤.៨០០ ដុល្លារអាមេរិក ក្នុងការជួយកសាងខ្លោងទ្វារ នៅច្រកទ្វារខាងត្បូង នៃ សាលាបឋមសិក្សា ចតុមុខ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ១០ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៧...ស.សរ

សេចក្តីសំរេច

ស្តីពីការចាត់តាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១៣ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៦១៧ អនក្រ.តត ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុង ឥស្សរជន និង អគ្គលេខាធិការ អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា
- យោងតាមការងាចាំបាច់

សម្រេច

ប្រការ ១ : ត្រូវបានចាត់តាំងឯកឧត្តម ចៅ តុល នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលបន្ទុកការងារកាកបាទក្រហមកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុង ប្រធានកាកបាទក្រហមកម្ពុជា ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១០ ឆ្នាំ ២០០៧

កន្លែងទទួល :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣ សសរ

សេចក្តីសំរេច

ស្តីពីការកែសម្រួលសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិ

គ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា

៚៚*៙៙

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨ ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-យោងអនុស្សារណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤

-យោងអនុស្សារណៈស្តីពីការរៀបចំចាត់ចែង ទាក់ទងនឹងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៧

-យោងសេចក្តីសំរេចលេខ២៥ សសរ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា

-តាមសំណើររបស់ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា

សំរេច

ប្រការ១.- ត្រូវបានកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា គណៈកម្មការប្រតិបត្តិ ក្រុមពិគ្រោះយោបល់ និងប្រធានលេខាធិការដ្ឋាន ទបសស ខេត្ត ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ជាអនុប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង ជំនួយផ្នែក ព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា និង ជាអនុប្រធានគណៈកម្មការប្រតិបត្តិ ជំនួសឯកឧត្តម **អ៊ុំ ជន** ដែលបានទទួលមរណៈភាព

២-ឯកឧត្តម **ឈុន ស៊ីរុន** អភិបាលខេត្តកណ្តាល ជាសមាជិកគណៈកម្មាការប្រតិបត្តិជំនួសឯកឧត្តម **ឃឹម បូរ** ដែលត្រូវទទួលភារកិច្ចថ្មី

៣-លោក **អ៊ូ សំអួន** អភិបាលរងខេត្តកណ្តាលជាសមាជិកក្រុមពិគ្រោះយោបល់ និងជាប្រធានលេខាធិការដ្ឋាន ទបសស ខេត្ត (ជនបង្គោលផ្នែក ទបសស ខេត្ត) ជំនួសលោក **ចេង ញ៉ាន់** ដែលត្រូវទទួលភារកិច្ចថ្មី

៤-លោក **ពៅ ម៉ុនធឿន** ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ជាសមាជិកបន្ថែមនៅក្នុងគណៈកម្មាការប្រតិបត្តិ

៥- លោក **ចេង ញ៉ាន់** មន្ត្រីក្រសួងមហាផ្ទៃ ជាសមាជិកបន្ថែមនៅក្នុងក្រុមពិគ្រោះយោបល់

ប្រការ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា និងសាម៉ីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០០៧

ស ៦៦២

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ ១៤០ ស.សរ

សេចក្តីសម្រេច
ស្តីពី
ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបង់វិភាគទានស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជារដ្ឋមន្ត្រីអាណាព្យាបាលរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមតម្រូវការចាំបាច់នៃការងារ

ស ម្រេ ច

ប្រការ ១.-

ត្រូវបានអនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវ នៅរាជបណ្ឌិតសភាកម្ពុជា ។ ការបណ្តុះបណ្តាលនេះ សំដៅរួមចំណែកអភិវឌ្ឍធនធានបញ្ញាញាណជាន់ខ្ពស់របស់ជាតិ ប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុត ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹងជាមូលដ្ឋាន ។

ប្រការ ២.-

ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា ត្រូវឈរលើមូលដ្ឋានសម្ភារៈបរិក្ខារ និងអគារសិក្សា ដែលមានស្រាប់នៅរាជបណ្ឌិតសភាកម្ពុជា ។

ប្រការ ៣.-

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា គ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រង ។ គណៈកម្មការគ្រប់គ្រងមានគណៈកម្មការប្រតិបត្តិជាសេនាធិការ ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន គណៈកម្មការគ្រប់គ្រង មានក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រសម្រាប់ពិគ្រោះយោបល់ ។

រចនាសម្ព័ន្ធ និងសមាសភាពគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

ប្រការ ៤.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

ប្រការ ៥.-

បេក្ខជនបណ្ឌិតដែលបានសិក្សា ស្រាវជ្រាវ និងការពារនិក្ខេបបទដោយជោគជ័យ ត្រូវទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ដោយរាជបណ្ឌិតសភាកម្ពុជា ដោយមានការទទួលស្គាល់ពីទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦.-

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជាមានប្រភពថវិកាមកពី ៖

- ការបង់ថ្លៃសិក្សារបស់បេក្ខជនបណ្ឌិត
- អំណោយ ឬជំនួយហិរញ្ញវត្ថុពីស្ថាប័នជាតិ និងអន្តរជាតិ
- ការងារសិក្សាស្រាវជ្រាវ និងប្រឹក្សាយោបល់

- ការលក់ឯកសារ ដែលបានបោះពុម្ពផ្សាយ និងពីប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត។

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា មានស្វ័យភិបាលហិរញ្ញវត្ថុ។

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា មានគណនីដោយឡែករបស់ខ្លួន។

ប្រការ ៧.–

ក្នុងការបំពេញភារកិច្ច គណៈកម្មការគ្រប់គ្រងមានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន។

ប្រការ ៨.–

គណៈកម្មការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា និងសមាសភាពគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបរិភាគទានស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា ដូចមានចែងក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជារដ្ឋមន្ត្រីទទួលបន្ទុករាជបណ្ឌិតសភាកម្ពុជា

សុខ អាន

<u>ចម្លងជូន</u>

- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- រាជបណ្ឌិតសភាកម្ពុជា
- ដូចប្រការ ៨
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ៩០ សសរ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៧

រចនាសម្ព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបង់ថ្លៃតាមខាងស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា



បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

[illegible]ព្យាបាល

សុខ អាន

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ៩០ សសរ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៧

សមាសភាពគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតបច់ចិភាគធានស្រាវជ្រាវ នៅរាជបណ្ឌិតសភាកម្ពុជា

១. គណៈកម្មការគ្រប់គ្រង

១-	ឯកឧត្តម ស៊ុំ ម៉ានិត	ទីប្រឹក្សារាជរដ្ឋាភិបាល និងជា ទីប្រឹក្សាសកម្មអមរាជបណ្ឌិតសភាកម្ពុជា ទទួលបន្ទុកកិច្ចការសម្របសម្រួលទូទៅក្នុង ការងារទំនាក់ទំនងអន្តរជាតិ	ប្រធាន
២-	ឯកឧត្តមបណ្ឌិត រស់ ចន្ត្រាបុត្រ	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	អនុប្រធាន
៣-	ឯកឧត្តមបណ្ឌិត ជា ណេង	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	លេខាធិការអចិន្ត្រៃយ៍
៤-	ឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និងជា ប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
៥-	ឯកឧត្តមបណ្ឌិត សំ សោភាន់	ប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម	សមាជិក
៦-	ឯកឧត្តមបណ្ឌិត សាបូ អូហ្សាណូ	អគ្គលេខាធិការរងនៃរាជបណ្ឌិតសភាកម្ពុជា ទទួលបន្ទុកបណ្តុះបណ្តាល ស្រាវជ្រាវ និង បោះពុម្ពផ្សាយ	សមាជិក
៧-	លោកបណ្ឌិត សុខ ទូច	អនុប្រធានវិទ្យាស្ថាន ទំនាក់ទំនងអន្តរជាតិកម្ពុជា	សមាជិក
៨-	លោកបណ្ឌិត អ៊ីវ ច័ន	អនុប្រធានវិទ្យាស្ថានភាសាជាតិ	សមាជិក
៩-	លោកបណ្ឌិត នូ ចាន់សុភី	លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក

២. ក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រ

១-	ឯកឧត្តមបណ្ឌិត ស៊ន សំណាង	ប្រធានរាជបណ្ឌិតសភាកម្ពុជា	ប្រធាន
២-	ឯកឧត្តមបណ្ឌិតវង្ស តិច សំណាង	អនុប្រធានក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាកម្ពុជា	

៣- លោកជំទាវបណ្ឌិត ខ្លួត ធីតា	អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា	អនុប្រធាន
៤- ឯកឧត្តមបណ្ឌិត ស៊ុំ ឈុំប៊ុន	អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា	អនុប្រធាន
៥- លោកបណ្ឌិត សោម សុមុនី	អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម	លេខាធិការ
៦- ឯកឧត្តមបណ្ឌិត ប៉ែន ដារេត	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល និងជាទីប្រឹក្សាសកម្មអមរាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ និងការសិក្សាអន្តរជាតិ	សមាជិក
៧- ឯកឧត្តមបណ្ឌិត ព្រុំ ម៉ល់	ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកភាសាវិទ្យានៅរាជបណ្ឌិត្យសភាកម្ពុជា	សមាជិក
៨- ឯកឧត្តមបណ្ឌិត ប៉ែន ប៊ុនពីវ	អនុប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម	សមាជិក
៩- លោកបណ្ឌិត គា គីរីវេណុល	អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា	សមាជិក
១០- លោកបណ្ឌិត នេង វណ្ណសិទ្ធិ	ប្រធានផ្នែកសេដ្ឋកិច្ច និងនីតិសាស្ត្រនៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម	សមាជិក
១១- លោកស្រីបណ្ឌិត សៀង ហ៊ុយ	ប្រធានផ្នែកគីមី និងចំណីអាហារ នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	សមាជិក
១២- លោកស្រីបណ្ឌិត ចេក សុថា	អនុប្រធានផ្នែកគីមី និងចំណីអាហារនៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	សមាជិក
១៣- លោកបណ្ឌិត នុត សម្បត្តិ	ប្រធានផ្នែកបរិស្ថាន ធម្មជាតិ និងជីវវិទ្យា នៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម	សមាជិក
១៤- លោកបណ្ឌិត ហាក់ ធីរោ	ប្រធានផ្នែកព័ត៌មានវិទ្យា និងទូរគមនាគមន៍នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	សមាជិក
១៥- លោកបណ្ឌិត ស៊ុន សូត	ប្រធានផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម	សមាជិក

១៦- លោកបណ្ឌិត ហ៊ីម សុភី	ប្រធានផ្នែកសិល្បៈប្រជាប្រិយ នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក

៣_ គណៈកម្មការប្រតិបត្តិ

១- លោកបណ្ឌិត សុខ ទូច	អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា	ប្រធាន
២- លោកបណ្ឌិត អ៊ាប ប៊ុណ្ណា	ប្រធានផ្នែករូបវិទ្យា និងថាមពល នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	អនុប្រធានទទួលបន្ទុកផ្នែកសិក្សាធិការ
៣- លោក ឯម សុវណ្ណារ៉ា	មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា	អនុប្រធានទទួលបន្ទុកផ្នែករដ្ឋបាល និងហិរញ្ញកិច្ច
៤- លោក គិន ភា	មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា	ប្រធានការិយាល័យរដ្ឋបាល
៥- លោក សូត្រ សំណាង	មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម	ប្រធានការិយាល័យហិរញ្ញកិច្ច
៦- លោក គី សេរីវឌ្ឍន៍	មន្ត្រីវិទ្យាស្ថា...នាក់ទំនងអន្តរជាតិកម្ពុជា	ប្រធានការិយាល័យទីផ្សារ និងបោះពុម្ពផ្សាយ
៧- លោក ជូ ច័ន្ទដារី	ប្រធានផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជា	ប្រធានការិយាល័យកិច្ចការនិស្សិត
៨- លោក ដាវ អានសាន	មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា	ប្រធានការិយាល័យកម្មវិធីសិក្សា
៩- លោកស្រី ជា វណ្ណី	មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម	ប្រធានការិយាល័យស្រាវជ្រាវ

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជារដ្ឋមន្ត្រីអាណាព្យាបាល

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១០១៤ ឧរថ.ករ.ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៨៥១ ពណ.នតក ចុះថ្ងៃទី២៤.០៣.២០០៦ របស់ក្រសួងពាណិជ្ជកម្ម
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អេឃ្វើ ឃីង អ៊ិនវេសមេន ខនស្ត្រាក់សិន អ៊ីមផត អិចផត ចុះថ្ងៃទី១២.០៩.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អេឃ្វើ ឃីង អ៊ិនវេសមេន ខនស្ត្រាក់សិន អ៊ីមផត អិចផត (AQUA KING INVESTMENT CONSTRUCTION IMPORT EXPORT CO,.LTD.) តំណាងដោយ លោក ហេង វ៉ាន់ឌី សញ្ជាតិខ្មែរ អាយុ៣២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010550479 ចុះថ្ងៃទី០៧.០៣.២០០៦ បង្កើតរោងចក្រ "ផលិតទឹកបរិសុទ្ធ " ដែលមានឈ្មោះថា " អេឃ្វើ ឃីង អ៊ិនវេសមេន ខនស្ត្រាក់សិន អ៊ីមផត អិចផត (AQUA KING INVESTMENT CONSTRUCTION IMPORT EXPORT)" មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ភូមិកន្ទោក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "ផលិតទឹកបរិសុទ្ធ " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចូន់ចូរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អេឃ្មី យ៉ឹង អ៊ិនវេសមេន ខនស្ត្រាក់សិន អ៊ីមផត អិចផត ត្រូវអនុវត្តប្រកាសនេះតាម មុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

ស៊ុយ សែម

ឆ្នាំ ទី ៧ លេខ ៧៨ សប្តាហ៍ទី ៣ ថ្ងៃ ទី ២៣ ខែ តុលា ឆ្នាំ ២០០៧ រាជកិច្ច ទំព័រ ៨៦១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១៤១៥ ឧស៊ី.ភ.ក-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០៣៤ ពណ.នគក ចុះថ្ងៃទី០៩.០១.២០០៣ របស់ក្រសួងពាណិជ្ជកម្ម
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អេស្យា ហ្វារអ៊ើ ម៉ាយល៍ ខបភរេហ្សិន ចុះថ្ងៃទី១៧.០៩.២០០៧

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អេស្យា ហ្វារអ៊ើ ម៉ាយល៍ ខបភរេហ្សិន (ASIA FLOUR MILL CORPORATION LTD) តំណាងដោយ លោក ខូវ គឹមបាក់ សញ្ជាតិខ្មែរ អាយុ៦២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010000949 ចុះថ្ងៃទី២៥.១១.២០០៥ បង្កើតរោងចក្រ "ផលិតម្សៅមី " ដែលមានឈ្មោះថា " អេស្យា ហ្វារអ៊ើ ម៉ាយល៍ ខបភរេហ្សិន (ASIA FLOUR MILL CORPORATION)" មានទីតាំងស្ថិតនៅ លេខ២២៨ វិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ប្រការ២: ក្រុមហ៊ុនត្រូវអនុវត្ត និងគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "ផលិតម្សៅមី" ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ ពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អេស្យា ហ្វាវអ៊ី ម៉ាយល៍ ខបភរេហ្សិន ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៤៥០ ប្រក.កសក

ប្រកាស
ស្តីពី
ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើតាបែន

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

សម្រេច

ប្រការ ១: បង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើមួយកន្លែងមានឈ្មោះថា **ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើតាបែន** មានទីតាំងនៅលើផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ស្ថិតនៅ ឃុំស្លរក្រោម និង ឃុំតាបែន ស្រុកស្វាយចេក ខេត្ត បន្ទាយមានជ័យ ។

ប្រការ ២: ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើតាបែនក្នុងគោលបំណង :

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់វិស័យសេដ្ឋកិច្ច
- បំផុសការចូលរួមដាំឈើរបស់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- អភិវឌ្ឍចំណេះដឹងវិស័យព្រៃឈើដល់សហគមន៍មូលដ្ឋាន
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការលួចឆាយ និង ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើដើម្បីជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ ដោយបង្កើនផលិតផលឈើពីព្រៃដាំ
- អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ច សង្គម និង បរិស្ថាន ។

ប្រការ ៣: ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើតាបែនមានផ្ទៃក្រឡាសរុបទំហំ ៧.០៤៨ ហិកតា (ប្រាំពីរពាន់សែសិបប្រាំបីហិកតា) រួមមានចំនួន ២តំបន់ ដូចមានផែនទីមាត្រដ្ឋាន១:១០០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធ។

- <u>នៅតំបន់ទី១</u>មានផ្ទៃដីចំនួន ១.៨០០ ហិកតា កំណត់ដោយចំណុចនិយាមកាជាប្រព័ន្ធខ្សែព្រំបិទដូចខាងក្រោម:

A1 (272000, 1530800) A2 (273300, 1530000) A3 (276300,1526000) A4 (276560,1524015) A5(273000,1524016) A6 (270989,1526000) A7 (272000,1526000) A8(272000,1527094) A9 (274072, 1526990) A10(274348,1528001) A11(272000, 1528332) ។

- <u>នៅតំបន់ទី២</u>មានផ្ទៃដីចំនួន ៥.២៤៨ ហិកតា កំណត់ដោយចំណុចនិយាមកាជាប្រព័ន្ធខ្សែព្រំបិទដូចខាងក្រោម:

B1 (276950, 1521050) B2 (272550, 1517000) B3 (264000,1519200) B4(259600,1522300) B5 (264100,1521300) B6(264200,1523600) B7 (264926,1523611) B8 (264926, 1521665) B9(264423,1521665)B10(264423,1521065) B11(265423, 1521065) B12(265423, 1521665) B13(268332, 1521640) B14(268332, 1520540) B15(270632, 1520540) B16(270632,1521640) B17(268829, 1521640) B18(268829, 1522617) B19 (265446,1522681) B20 (265440,1523619) B21(270000, 1523700) B22(271995,1521997) ។

ប្រការ ៤: ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើតាបែន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និង មានភារកិច្ចដូចតទៅ :

- ធ្វើការដាំឈើ ថែរក្សាការពារ និង ប្រមូលផលឈើដាំ
- សហការជាមួយដៃគូអភិវឌ្ឍន៍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ កែច្នៃ និងធ្វើអាជីវកម្ម
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេស ដល់សហគមន៍មូលដ្ឋាន
- ទាក់ទាញគាំទ្រជំនួយ ពីបណ្តាអង្គការអន្តរជាតិនានា ។

ប្រការ ៥: ដំណើរការ និង ការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើនេះត្រូវកំណត់ដោយសេចក្តីសម្រេច

របស់ប្រធានរដ្ឋបាលព្រៃឈើ ។

ប្រការ ៦: ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧: អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨..ខែ.១០...ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ច័ន្ទ.សារុន

កន្លែងទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-សាលាខេត្ត បន្ទាយមានជ័យ
-ដូចប្រការ ៧
-ឯកសារ-កាលប្បវត្តិ


Scale 1: 100 000
2Km

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៤៥១ ប្រក.កសក

ប្រ កា ស

ស្តីពី

ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្នួលទ្រេត

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពី ការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

ស ម្រេ ច

ប្រការ ១: បង្កើតស្ថានីយមួយកន្លែងមានឈ្មោះថា **ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្នួលទ្រេត** ដែលមានទីតាំងនៅលើផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ស្ថិតនៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ប្រការ ២: ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្នួលទ្រេតក្នុងគោលបំណង :

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់វិស័យសេដ្ឋកិច្ច

ទីស្នាក់ការលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax (855) 23 - 217 320

- បំផុសការចូលរួមដាំឈើរបស់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- អភិវឌ្ឍចំណេះដឹងវិស័យព្រៃឈើដល់សហគមន៍មូលដ្ឋាន
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការប៉ុនប៉ងកាន់កាប់ដីព្រៃឈើដើម្បីជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ ដោយបង្កើនផលិតផលឈើពីព្រៃដាំ
- អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ច សង្គម និង បរិស្ថាន ។

ប្រការ ៣: ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទួលទ្រេតមានផ្ទៃក្រឡាទំហំ ៣.៧៤៤ ហិកតា (បីពាន់ប្រាំពីររយចិតសិបបួនហិកតា) ដូចមានផែនទីមាត្រដ្ឋាន១:៥០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធ និង កំណត់ដោយចំណុចនិយាមការជាប្រព័ន្ធខ្សែព្រំបិទចាប់ពីចំណុច A (261000, 1509000) B (258000, 1512000) C (258000,1519000) D (259000,1519000) ដល់ចំណុច E (265000,1511000) ។

ប្រការ ៤: ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទួលទ្រេត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និង មានភារកិច្ច ដូចតទៅ :

- ធ្វើការដាំឈើ ថែរក្សាការពារ និង ប្រមូលផលឈើដាំ
- សហការជាមួយដៃគូអភិវឌ្ឍន៍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ កែច្នៃ និង ធ្វើអាជីវកម្មឈើដាំ
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសដល់សហគមន៍មូលដ្ឋាន
- ទាក់ទាញគំរោងជំនួយ ពីបណ្តាអង្គការអន្តរជាតិនានា ។

ប្រការ ៥: ដំណើរការ និង ការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

ប្រការ ៦: ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧: អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី...១៩...ខែ...ឧសភា...ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ច័ន្ទ សារុន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ


(258000,1519000)
C
D (259000,1519000)
B
(258000,1512000)
A (261000,1508000)
E
(265000,1511000)
ខេត្តបន្ទាយមានជ័យ
សញ្ញាសំគាល់
ឈ្មោះឃុំ
ព្រំប្រទល់ឃុំ
ផ្លូវ
ព្រំប្រទល់ស្នើសុំ
ព្រៃស្រោង
មាត្រដ្ឋាន ១ : ៥០ ០០០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ * ៣៣

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ : ...៤២៧... ប្រក.សក.បធ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧

ប្រកាស
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំៗ

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.៩៤.០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស.៩៤.០៦ ចុះថ្ងៃ ទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រី-រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៣ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសេចក្តីត្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

សម្រេច

ប្រការ ១ : មជ្ឈមណ្ឌលគ្រឿងចក្រធំៗស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានសាធារណការនៃក្រសួងសាធារណការ និងដឹកជញ្ជូន ហើយដែលមានតួនាទីភារកិច្ចដូចមានចែងក្នុងមាត្រា ១៣នៃអនុក្រឹត្យលេខ ១៤ អនក្រ.បក. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដូចខាងក្រោម ÷

១-១ សិក្សាស្រាវជ្រាវធ្វើគំរោង និងស្ថាបនាការងារថ្មី :

- សិក្សាស្រាវជ្រាវ និងលើកគំរោងស្ថាបនា ផ្លូវ-ស្ពាន
- អនុវត្តការស្ថាបនា ផ្លូវ-ស្ពាន និងការងារជួសជុលធំ
- អន្តរាគមន៍ដល់ការងារជួសជុលបន្ទាន់ ។

១-២ គ្រប់គ្រង និង ត្រួតពិនិត្យបរិក្ខារ-គ្រឿងចក្រនៅក្រោមរាជធានីណាព្យាបាល :

- រៀបចំ និងផ្សព្វផ្សាយបទដ្ឋានបច្ចេកទេស ក្នុងការប្រើប្រាស់ ថែទាំគ្រឿងចក្រដល់អង្គភាពមូលដ្ឋាន
- គ្រប់គ្រងសំភារៈគ្រឿងចក្រគ្រប់ប្រភេទ ដែលប្រើសំរាប់ការងារសាធារណការ ។

១-៣ សិក្សា និងរៀបចំបណ្តុះបណ្តាលបុគ្គលិកជំនាញខាងគ្រឿងចក្រ :

- សិក្សាស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិស្តីពី សុវត្ថិភាពការងារ និងអនាម័យ
- បណ្តុះបណ្តាលជំនាញបើកបរ បញ្ជាគ្រឿងចក្រគ្រប់ប្រភេទ សំរាប់ការងារសាធារណការ

មជ្ឈមណ្ឌលគ្រឿងចក្រធំ១ទទួលបន្ទុកអនុវត្តការងារជំនាញឯកទេសមួយចំនួនទៀតតាមការប្រគល់ភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួង ។

ប្រការ ២ : • មជ្ឈមណ្ឌលគ្រឿងចក្រធំ១ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់

• ការិយាល័យចំណុះមជ្ឈមណ្ឌលដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់

• អង្គភាពមូលដ្ឋានមានថ្នាក់ស្មើការិយាល័យចំណុះមជ្ឈមណ្ឌល ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ ៣ : មជ្ឈមណ្ឌលគ្រឿងចក្រធំ១ ត្រូវបានបែងចែកជាការិយាល័យ និងអង្គភាពមូលដ្ឋាននៅក្រោមចំណុះដូចខាងក្រោម ÷

៣-១ ការិយាល័យ ស្ថិតក្រោមចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំ១ :

- ការិយាល័យ រដ្ឋបាល បុគ្គលិក-ធនធានមនុស្ស
- ការិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ
- ការិយាល័យ ផែនការ-បច្ចេកទេស ។

៣-២ អង្គភាពមូលដ្ឋានមានថ្នាក់ស្មើការិយាល័យ ស្ថិតក្រោមចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំ១ :

- មូលដ្ឋាន ស្ថាបនាផ្ទាល់ (RCC)
- អង្គភាព អន្តរាគមន៍ សាធារណការ (IPUW)។

ប្រការ ៤ : តួនាទី និងភារកិច្ចការិយាល័យចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំ១ ÷

៤-១ ការិយាល័យ រដ្ឋបាល បុគ្គលិក-ធនធានមនុស្ស :

- គ្រប់គ្រងមន្ត្រីរាជការក្នុងក្របខ័ណ្ឌមជ្ឈមណ្ឌលអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលរាល់កិច្ចការទូទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំ១

- គ្រប់គ្រងឯកសាររដ្ឋបាល ធានាប្រសិទ្ធភាព-សុវត្ថិភាព និងចរាចរឱ្យទាន់ពេលវេលា
- គ្រប់គ្រងការងារ សន្តិសុខ សណ្តាប់ធ្នាប់បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌល ហើយបើមានការងារចាំបាច់ផ្សេងទៀត ត្រូវសុំយោបល់ពីថ្នាក់ដឹកនាំមជ្ឈមណ្ឌល និងធ្វើការណែនាំផ្ទាល់ទៅអង្គភាពពាក់ព័ន្ធ
- រៀបចំបែបបទស្នើសុំតម្លើងថ្នាក់មុខតំណែង និងឋានន្តរស័ក្តិដល់មន្ត្រីរាជការ
- ចាត់មន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលធ្វើកម្មសិក្សា ទស្សនកិច្ច បន្តការសិក្សាក្នុង និងក្រៅប្រទេសតាមការកំណត់របស់ក្រសួង
- រៀបចំបែបបទធានារ៉ាប់រងសង្គមដល់ជនបាត់បង់សមត្ថភាពពលកម្ម និវត្តជន និងមរណជន
- រៀបចំបែងចែកភារកិច្ចដល់មន្ត្រីរាជការ ទៅតាមសមត្ថភាពជំនាញ និងបទពិសោធន៍ការងារ
- ចូលរួមរៀបចំបទប្បញ្ញត្តិស្តីពីសុវត្ថិភាពការងារ និងអនាម័យក្នុងការប្រើប្រាស់គ្រឿងចក្រនៅតាមអង្គភាពមូលដ្ឋាន
- រៀបចំវគ្គបណ្តុះបណ្តាលបើកបរ និងថែទាំគ្រឿងចក្រ
- សរុបរបាយការណ៍ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ អំពីសកម្មភាពការងាររបស់មជ្ឈមណ្ឌលជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល និងក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

៤-២ ការិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ :

- គ្រប់គ្រងការងារហិរញ្ញវត្ថុ ក្នុងការស្ថាបនា ផ្លូវ-ស្ពាន
- គ្រប់គ្រង ត្រួតពិនិត្យការប្រើប្រាស់ថវិកាឱ្យបានត្រឹមត្រូវ តាមដីកាចំណូល និងធានាចំណាយ
- កំណត់ខ្ទង់ចំណូល និង ចំណាយតាមច្បាប់ និងបទបញ្ជា
- គ្រប់គ្រងសាច់ប្រាក់ក្នុងបេឡា
- ចូលរួមទទួលខុសត្រូវ អនុវត្តផ្នែកលទ្ធកម្មសាធារណៈក្នុងក្របខ័ណ្ឌរបស់មជ្ឈមណ្ឌល
- កសាងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ចលនវត្ថុ អចលនវត្ថុប្រចាំឆ្នាំ
- សហការត្រួតពិនិត្យកិច្ចការជំរះបញ្ជីទ្រព្យសម្បត្តិរដ្ឋ
- តាមដានតំលៃសំភារៈ គ្រឿងបន្លាស់រថយន្ត គ្រឿងចក្រនៅទីផ្សារ ដើម្បីជាមូលដ្ឋាននៃការរៀបចំថវិកាជួសជុល គ្រឿងចក្រនៅក្នុងអង្គភាព ។
- ធ្វើរបាយការណ៍ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

៤-៣ ការិយាល័យផែនការ-បច្ចេកទេស :

- ធ្វើផែនការប្រចាំឆ្នាំ (ស្រាវជ្រាវ និងលើកគំរោង ជួសជុល ផ្លូវ -ស្ពាន តាមលំដាប់អាទិភាពក្នុងក្របខ័ណ្ឌមជ្ឈមណ្ឌលដោយរួមសហការជាមួយនាយកដ្ឋានផែនការ)
- ត្រួតពិនិត្យការងារជួសជុល និងស្ថាបនា ផ្លូវ-ស្ពាន និងគុណភាពសំភារៈសំណង់ នៅតាមការដ្ឋាន
- លើកគំរោងស្នើសុំជំនួយបរទេសតាមផែនការរបស់ក្រសួងដោយរួមសហការជាមួយនាយកដ្ឋានផែនការ
- ធ្វើបញ្ជីប៉ាន់តម្លៃការងារជួសជុល និងស្ថាបនា ផ្លូវ-ស្ពាន ដែលក្រសួងប្រគល់មកឱ្យមជ្ឈមណ្ឌល
- សិក្សាស្រាវជ្រាវ និងរៀបចំបទដ្ឋានបច្ចេកទេសសំណង់សាធារណការ

- រៀបចំ និងផ្សព្វផ្សាយបទដ្ឋានបច្ចេកទេស ក្នុងការប្រើប្រាស់ ថែទាំមធ្យោបាយ គ្រឿងចក្រដល់អង្គភាព-មូលដ្ឋាន
- រៀបចំទុកដាក់ឯកសារបច្ចេកទេស គំនូសប្លង់ ឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព
- ធ្វើរបាយការណ៍ប្រចាំខែ -ត្រីមាស -ឆមាស -ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗ ទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

ប្រការ ៥ : តួនាទី និងភារកិច្ចរបស់អង្គភាពមូលដ្ឋានចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំៗ

៥-១ មូលដ្ឋានស្ថាបនាផ្លូវ Road Construction Center (RCC)

- អនុវត្តការស្ថាបនា ផ្លូវ-ស្ពាន និងការងារជួសជុលធំតាមគំរោងផែនការប្រចាំឆ្នាំ របស់ក្រសួង ដែលមជ្ឈមណ្ឌលប្រគល់ជូន
- បញ្ជូនមន្ត្រីរាជការក្រោមឱវាទឱ្យមកបណ្តុះបណ្តាលមុខជំនាញបច្ចេកទេសបើកបរ និងថែទាំគ្រឿងចក្រ
- គ្រប់គ្រងរថយន្ត គ្រឿងចក្រ និងសំភារៈនានា ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់ ក្នុងមូលដ្ឋានដោយអនុវត្តតាមបទបញ្ជាផ្ទៃក្នុង
- ចូលរួមរៀបចំបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ ចលនវត្ថុ អចលនវត្ថុរបស់មជ្ឈមណ្ឌល
- រៀបចំ និងប្រើប្រាស់កម្លាំងពលកម្មឱ្យសមស្របតាមសមត្ថភាពជំនាញ
- រាយការណ៍បន្ទាន់ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល នៅពេលមានគ្រោះថ្នាក់ការងារ
- អនុវត្តគំរោងស្ថាបនា តាមកម្មវិធីការងារដែលបានគ្រោងទុក និងតាមបទដ្ឋាន បច្ចេកទេស ដែលបានកំណត់ក្នុងគំរោង
- ធ្វើរបាយការណ៍ប្រចាំខែ-ត្រីមាស- ឆមាស- ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

៥-២ អង្គភាពអន្តរាគមន៍ សាធារណការ Intervention Unit of Public Works (IUPW) :

- អន្តរាគមន៍ដល់ការងារជួសជុល ផ្លូវ-ស្ពាន បន្ទាន់ ឬដោយចៃដន្យ (ការងារឥតគ្រោងទុក) ដែលមជ្ឈមណ្ឌលប្រគល់ជូន
- ចាត់បញ្ជូនមន្ត្រីរាជការឱ្យមកបណ្តុះបណ្តាលលើមុខជំនាញបើកបរ និងថែទាំគ្រឿងចក្រ
- គ្រប់គ្រងរថយន្ត គ្រឿងចក្រ និងសំភារៈប្រើប្រាស់ ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់ ក្នុងមូលដ្ឋានដោយអនុវត្តតាមបទបញ្ជាផ្ទៃក្នុង
- ចូលរួមរៀបចំបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ ចលនវត្ថុ អចលនវត្ថុ របស់មជ្ឈមណ្ឌល
- រៀបចំ និងប្រើប្រាស់កម្លាំងពលកម្មឱ្យសមស្របតាមសមត្ថភាពជំនាញ
- រាយការណ៍ជាបន្ទាន់ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល នៅពេលមានគ្រោះថ្នាក់ការងារ
- ធ្វើរបាយការណ៍ ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗ ទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

ប្រការ ៦ : ប្រកាសលេខ៣៨៣ ប្រក សក បផ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំៗ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន អគ្គាធិការ នៃអាគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលគ្រឿងចក្រធំៗ នៃក្រសួងសាធារណការ និង ដឹកជញ្ជូនត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួនតាមខ្លឹមសារនៃប្រកាសនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុន ចាន់ថុល

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

"**ដើម្បីជ្រាបជាពត៌មាន**"

- ដូចប្រការ ៧
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់មន្ទីរសាធារណការខេត្ត-ក្រុង

"**ដើម្បីអនុវត្ត**"

-ឯកសារ-កាលប្បវត្តិ